ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការអនុវត្ត
# យុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ
# ឆ្នាំ ២០២២-២០២៦


រៀបចំដោយ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ



ឆ្នាំ២០២២

# អារម្ភកថា

រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយភាពប៉ិនប្រសប់ និងឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជាទទួលបាននូវការអភិវឌ្ឍន៍លើគ្រប់វិស័យ និងការរក្សាបាននូវសន្តិភាពជូនប្រជាពលរដ្ឋដើម្បីរស់នៅក្នុង សេរីភាព សេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាព ស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍នីតិរដ្ឋ។ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ចំពោះការអនុវត្តច្បាប់អន្តរជាតិនានា ជាពិសេសអនុសញ្ញា\ស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ និងកិច្ចការពារជាពិសេសសម្រាប់កុមារ ព្រមទាំងបានដាក់ ចេញនូវវិធានការជាច្រើន ដើម្បីធានាឱ្យបាននូវសុខុមាលភាព និងការគាំពារសង្គមចំពោះកុមារកម្ពុជា។ ទន្ទឹមគ្នានេះ កម្ពុជាបានការដាក់ចេញឱ្យអនុវត្តនូវច្បាប់ គោលនយោបាយ និងផែនការសកម្មភាពជាតិនានា ដូចជា ក្របខ័ណ្ឌ គោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥ គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

ដើម្បីធានាបាននូវឧត្តមប្រយោជន៍ និងសិទ្ធិជាមូលដ្ឋានរបស់កុមារចំពោះកុមារនៅក្នុងមណ្ឌល និងនៅតាមសហគមន៍ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យ ស្តីពីការកែសម្រួលរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ អនុក្រឹត្យលេខ១១៩ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ និងអនុក្រឹត្យលេខ៣៤ ស្តីពីការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលឱ្យទៅរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាល រាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ អនុក្រឹត្យលេខ ១៨២, ១៨៣, ១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ខណ្ឌ នៃរាជធានីភ្នំពេញ និងស្រុក និងបានចេញលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត។ នេះជាការយកចិត្តទុកដាក់បន្ថែមពីរាជរដ្ឋាភិបាលក្នុងការធ្វើឲ្យប្រសើរឡើងនូវការផ្តល់សេវាដល់ប្រជាជនក្រីក្រងាយរងគ្រោះ ជាពិសេស កុមារកំព្រា និងកុមាររងគ្រោះនៅតាមសហគមន៍ដោយបង្កើននូវការយកចិត្តទុកដាក់ពង្រឹងគុណភាព និងបង្វិតសេវាឱ្យទៅជិតជាមួយប្រជាជន តាមរយៈការបង្កើនល្បឿននៃការធ្វើវិមជ្ឈការដោយផ្ទេរការទទួលខុសត្រូវ និងវិភាជន៍ថវិកាទៅរដ្ឋបាលថ្នាក់ក្រោមជាតិជាបណ្តើៗ ប្រកបដោយសុទិដ្ឋិនិយមក្រៃលែង។

ថ្វីបើមានភាពរីកចម្រើនទាំងនេះក្តី បញ្ហាប្រឈមផ្នែកកិច្ចការពារកុមារគឺនៅតែមាន ដោយកុមារមួយចំនួននៅតែប្រឈមមុខនឹងអំពើហិង្សា កង្វះកម្លាំងសេវាសង្គម និងសេវាមួយចំនួនក្នុងការឆ្លើយតបចំពោះកុមារទាំងនេះ។ ដើម្បីធានាថាកុមារកម្ពុជាគ្រប់រូបមានឱកាសអភិវឌ្ឍន៍នៅក្នុងបរិយាកាសគ្រួសារប្រកបដោយជាសុកភាព សុវត្ថិភាព និងរួចផុតពីអំពើហិង្សា និងកេងប្រវ័ញ្ច គឺទាមទារនូវដំណើរការការរៀបចំផែនការ ការអនុវត្ត និងការតាមដានត្រួតពិនិត្យកាន់តែល្អប្រសើរឡើង។

ប្រទេសកម្ពុជាមានផែនការជាច្រើនដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ត្រូវបានរៀបចំឡើងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរួមទាំងផែនការជាក់លាក់ទៅតាមក្រសួង និងទីភ្នាក់ងារនានា ដែលរួមបញ្ចូលនូវកិច្ចការពារកុមារជាផ្នែកមួយនៃសកម្មភាពដ៏មានសារៈសំខាន់។ ទោះបីជាយ៉ាងណាក្តី ការវាយតម្លៃទៅតាមវិស័យ និងក្របខណ្ឌការងារមួយដើម្បីផ្តល់មូលនិធិ និងតាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការ និងក្របខណ្ឌនោះនៅមានចន្លោះប្រហោង ដែលបង្អាក់សមត្ថភាពរបស់ថ្នាក់ជាតិក្នុងការបង្កើតប្រព័ន្ធកិច្ចការពារកុមារមួយដែលមានដំណើរការពេញលេញ និងប្រកបដោយប្រសិទ្ធភាព។ ហេតុនេះដំណោះស្រាយយ៉ាងមានប្រសិទ្ធភាពចំពោះបញ្ហាកិច្ចការពារកុមារនៅកម្ពុជា ទាមទារនូវការរៀបចំផែនការ ការផ្តល់ហិរញ្ញប្បទាន និងការអនុវត្តរួមគ្នា។ កិច្ចសហការនៅក្នុង ចំណោមតួអង្គតាមវិស័យកិច្ចការពារកុមារ គឺជាការចាំបាច់សម្រាប់កម្ពុជា ក្នុងការបំពេញការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះទិសដៅនានានៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ព្រមទាំងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ដែលទាមទារការពង្រឹងស្ថាប័នសាធារណៈទាំងអស់។

ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦ នេះ គឺជាផែនការមួយដែលមិនជំនួសឱ្យផែនការជាក់លាក់នានាអំពីវិស័យខុសៗគ្នានៃកិច្ចការពារកុមារឡើយ។ ផែនការនេះបន្ថែមគុណតម្លៃតាមរយៈការប្រមូលផ្តុំនូវអាទិភាពសំខាន់ៗទាំងអស់ឱ្យនៅមួយកន្លែង ដោយបញ្ចូលសមាសធាតុសំខាន់ៗ នៃផែនការជាក់លាក់ដទៃទៀត និងពង្រឹងសមិទ្ធិកម្មតាមវិស័យដោយការបង្កើនភាពជាប់ពាក់ព័ន្ធ និងការជួយគាំទ្របន្ថែមទៅលើអន្តរាគមន៍នានា។ ផែនការនេះបានរៀបចំជាកម្មវិធីគន្លឹះចំនួនប្រាំ និងមានបំណងបង្កើតប្រព័ន្ធកិច្ចការពារកុមារមួយដែលមានដំណើរការប្រកបដោយប្រសិទ្ធភាព ការសម្របសម្រួលកិច្ចសហប្រតិបត្តិការល្អ មានធនធាន និងនិរន្តរភាព។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិក សមាជិកា នៃក្រុមការងារបច្ចេកទេសរបស់ក្រសួងទាំងពីរ ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងអរគុណចំពោះទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ និងមូលនិធិសហប្រជាជាតិដើម្បីកុមារ និងអ្នកពាក់ព័ន្ធដទៃទៀតចំពោះកិច្ចខិតខំប្រឹងប្រែង និងការគាំទ្រក្នុងការរៀបចំផែនការដ៏មានសារៈសំខាន់នេះ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ សូមអំពាវនាវដល់ម្ចាស់ជំនួយជាតិ-អន្តរជាតិ ទីភ្នាក់ងារសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ បន្តការគាំទ្រទាំងបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីជំរុញការអនុវត្តផែនការនេះប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ថ្ងៃទីអង្គារ ៦កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រី**
**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**វង សូត**

# មាតិកា


អារម្ភកថា ..... i
បញ្ជីនៃអក្សរកាត់ ..... iv
សេចក្តីសង្ខេប ..... ១
ជំពូកទី ១ ..... ៤
សេចក្តីផ្តើម ..... ៤
១.១. សាវតា ..... ៤
១.២. ការផ្សារភ្ជាប់ជាមួយយុទ្ធសាស្ត្រ និងគោលនយោបាយជាតិ ..... ៦
១.៣. ដំណើរការនៃការរៀបចំផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ..... ៧
ជំពូកទី ២ ..... ៨
ការវិភាគស្ថានភាព និងការពិនិត្យលើផែនការសំខាន់ៗ ..... ៨
២.១. ការវិភាគស្ថានភាព (ចន្លោះ) ..... ៨
២.២. ការពិនិត្យលើផែនការពាក់ព័ន្ធសំខាន់ៗ ..... ៨
ជំពូកទី ៣ ..... ១២
និដ្ឋភាពនៃផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ..... ១២
៣.១. ចក្ខុវិស័យ គោលបំណង និងគោលដៅ ..... ១២
៣.២. គោលការណ៍សំខាន់ៗ ..... ១២
៣.៣. កម្មវិធី គោលបំណង លទ្ធផលរំពឹងទុក លទ្ធផល និងសកម្មភាព ..... ១៣
កម្មវិធីទី១៖ ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងពង្រឹងប្រព័ន្ធប្រតិបត្តិការ ..... ១៣
កម្មវិធីទី២៖ ការពង្រឹង និងពង្រីកសេវាគោលដៅក្នុងការបង្ការទប់ស្កាត់ និងសេវាគាំទ្រ ..... ១៦
កម្មវិធីទី៣៖ ការពង្រឹង និងពង្រីកសេវាផ្សព្វផ្សាយ ..... ១៨
កម្មវិធីទី៤៖ ការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ ..... ១៨
កម្មវិធីទី៥៖ ការបង្កើតយន្តការសម្របសម្រួល ..... ១៩
៣.៤. ក្របខ័ណ្ឌផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦ ..... ២០
ជំពូកទី ៤ ..... ២៦
ការប៉ាន់ស្មានចំណាយ និងយុទ្ធសាស្ត្រហិរញ្ញប្បទានសម្រាប់អនុវត្តផែនការអនុវត្ត
យុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦ ..... ២៦
ជំពូកទី ៥ ..... ៣១
ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ..... ៣១
ជំពូកទី ៦ ..... ៣៦
សេចក្តីសន្និដ្ឋាន ..... ៣៦

# បញ្ជីនៃអក្សរកាត់

| | |
|---|---|
| 3PC | កម្មវិធីភាពជាដៃគូដើម្បីកិច្ចការពារកុមារ |
| CNCC | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| CCWC | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| CPiE | កិច្ចការពារកុមារក្នុងស្ថានភាពអាសន្ន |
| DoSVY | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| FCF I REACT | គម្រោងថែទាំកុមារក្នុងគ្រួសារជាអាទិភាព និងឆ្លើយតបដោយប្រសិទ្ធភាពដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធសុខុមាលភាពកុមារ |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoI | ក្រសួងមហាផ្ទៃ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| NISA | វិទ្យាស្ថានជាតិសង្គមកិច្ច |
| SSWF | កម្លាំងសេវាសង្គម |
| UNICEF | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ |
| WCCC | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) |

# សេចក្ដីសង្ខេប

**សាវតាទូទៅចំពោះការរៀបចំផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ រួមមាន សេចក្ដីពណ៌នាសង្ខេបអំពីដំណើរការនេះ និងការចូលរួមរបស់អ្នកពាក់ព័ន្ធសំខាន់ៗ៖**

នាពេលកន្លងមកនេះ វិស័យកិច្ចការពារកុមារ និងសុខុមាលភាពសង្គមនៅកម្ពុជា មានការផ្លាស់ប្ដូរគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងការផ្ដល់សេវាសង្គមនៅពេលបច្ចុប្បន្ន។ កុមារនៅកម្ពុជាទទួលបានកិច្ចការពារកាន់តែប្រសើរឡើងតាមរយៈការលើកកម្ពស់ប្រព័ន្ធច្បាប់ និងសេវានានា ក្រោមការជួយគាំទ្រពីរាជរដ្ឋាភិបាល និងជំនួយអភិវឌ្ឍន៍សម្រាប់វិស័យនេះ។ ជាពិសេសនៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ កម្ពុជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងការបង្កើតយន្តការជាមូលដ្ឋានសម្រាប់កិច្ចការពារកុមារ ការធ្វើសមាហរណកម្មកុមារចេញពីមណ្ឌលថែទាំជំនួស ការប្រយុទ្ធប្រឆាំងដើម្បីបញ្ឈប់អំពើហិង្សាលើកុមារ រួមទាំងក្លាយជាប្រទេសសមាជិកនៃប្រទេសដៃគូសកល ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ។

ការលើកកម្ពស់ និងការឆ្លើយតបចំពោះកិច្ចការពារកុមារ កម្ពុជាមានផែនការជាច្រើន ដែលពាក់ព័ន្ធនឹងទិដ្ឋភាពផ្សេងៗរបស់កិច្ចការពារកុមារ។ លើសពីនេះ ក្រសួងនិងស្ថាប័ននានា ក៏តែងមានផែនការជាក់លាក់របស់ខ្លួន ហើយផែនការទាំងនេះក៏មានដាក់បញ្ចូលការងារកិច្ចការពារកុមារជាផ្នែកមួយ នៃផែនការសកម្មភាពទាំងមូលរបស់ខ្លួន។ ជាការចូលរួមចំណែកក្នុងការឆ្លើយតបនឹងការការពារកុមារឱ្យបានកាន់តែស៊ីជម្រៅ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ ក្រោមការគាំទ្របច្ចេកទេសពី UNICEF បានលើកជាគំនិតផ្ដួចផ្ដើមក្នុងការរៀបចំជាផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ។ ផែនការនេះមានគោលបំណងជំរុញ និងពង្រីកសកម្មភាពកិច្ចការពារកុមារឱ្យបានកាន់តែទូលំទូលាយនៅកម្រិតថ្នាក់ក្រោមជាតិ។

កិច្ចពិភាក្សាដំបូងជាមួយភាគីពាក់ព័ន្ធត្រូវបានផ្ដួចផ្ដើមឡើងនៅឆ្នាំ២០១៩។ ដំណើរការនេះ រួមមាន ការរៀបចំ និងការចែករំលែកឯកសារទស្សនទាននៅឆ្នាំ២០១៩ ការកំណត់ចក្ខុវិស័យ នៃកិច្ចការពារកុមារជាមួយអង្គការមិនមែន រដ្ឋាភិបាលពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នៅឆ្នាំ២០២០ និងសិក្ខាសាលាដំបូងដែលសហការដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីពិភាក្សាជុំទីមួយទៅលើក្របខ័ណ្ឌទស្សនទាន គោលបំណង និងចំណាត់ការអាទិភាពសំខាន់ៗដែលត្រូវបានស្នើឡើងនៅឆ្នាំ២០២០។ នៅឆ្នាំ២០២០ ក្រុមការងារបច្ចេកទេសមួយត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យដំណើរការជារួម នៃការរៀបចំផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រោមការដឹកនាំរបស់ឯកឧត្ដម **នឹម ថូត** រដ្ឋលេខាធិការប្រចាំការ។ ដើម្បីបានជាធាតុចូលដាក់ជូនក្រុមការងារនេះ ការពិគ្រោះយោបល់មួយជាមួយអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ត្រូវបានរៀបចំឡើងនៅខែវិច្ឆិកា ក្រោមកិច្ចសហការសម្របសម្រួលដោយ UNICEF គម្រោង FCF|REACT និង 3PC។ បន្ទាប់មកមតិយោបល់ជាធាតុចូលនេះត្រូវបានចែករំលែកនៅក្នុងកិច្ចប្រជុំដំបូងនៃក្រុមការងារបច្ចេកទេសនេះ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០។ កិច្ចប្រជុំនៃក្រុមការងារបច្ចេកទេសនេះបានឯកភាពទៅលើគោលបំណងជាយុទ្ធសាស្ត្រចំនួនប្រាំ និងចំណាត់ការជាអាទិភាពសម្រាប់គោលបំណងនីមួយៗ។ តាមរយៈការចង្អុលបង្ហាញពីក្រុមការងារបច្ចេកទេស ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារនេះ ត្រូវបានរៀបចំជាសេចក្ដីព្រាងសម្រាប់ផែនការយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលកម្ពុជា។

## ទិដ្ឋភាពសង្ខេប នៃកម្មវិធីអាទិភាព និងគោលបំណងកម្មវិធី

ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ (CP-SSIP) នេះ ផ្ដោតជាក់លាក់លើទិដ្ឋភាពសំខាន់ៗ ចំនួនប្រាំដែលត្រូវបានកំណត់ជាកម្មវិធីចំនួនប្រាំ។ តារាងទី១ បង្ហាញពីគោលបំណង និងលទ្ធផលរំពឹងទុកសម្រាប់កម្មវិធីទាំងប្រាំដែលបានមកពីការអនុវត្តសកម្មភាពជាច្រើនជាអាទិភាពសម្រាប់កិច្ចការពារកុមារ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## តារាងទី ១៖ កម្មវិធី គោលបំណង និងលទ្ធផលរំពឹងទុក នៃផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ

| កម្មវិធី | គោលបំណងនៃកម្មវិធី | លទ្ធផលរំពឹងទុកនៃកម្មវិធី |
|---|---|---|
| **១.ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងពង្រឹងប្រព័ន្ធប្រតិបត្តិការ** | ១.ពង្រឹងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងប្រព័ន្ធប្រតិបត្តិការសម្រាប់ការពារកុមារពីការរំលោភបំពានគ្រប់ប្រភេទ ជាពិសេសនៅពេលមានករណីការពារកុមារត្រូវបានរាយការណ៍ (កុមារទាំងអស់រួមទាំងជនរងគ្រោះ សាក្សី និងជនល្មើស) | ១.មានប្រព័ន្ធកិច្ចការពារកុមារដោយមានកញ្ចប់ថវិកាធនធានមនុស្សនិងមធ្យោបាយគ្រប់គ្រាន់ (ឧទាហរណ៍៖ សមត្ថភាពក្នុងការស៊ើបអង្កេត និងវាយតម្លៃនៅពេលកុមារត្រូវបានគេចាត់ទុកថាប្រឈម ឬជាជនរងគ្រោះដោយអំពើហិង្សា ឬមានទំនាស់នឹងច្បាប់) និងជម្រើសថែទាំសមរម្យ សមស្របតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ |
| **២.ការពង្រឹង និងពង្រីកសេវាបង្ការទប់ស្កាត់ និងសេវាគាំទ្រ** | ២.ផ្តល់សេវាបង្ការទប់ស្កាត់ និងសេវាគាំទ្រសម្រាប់ក្រុមគោលដៅ និងគ្រួសារដែលរកឃើញថាមានហានិភ័យ (កម្រិតមធ្យម) | ២. កុមារនិងគ្រួសារដែលបានជួបប្រទះ ឬប្រឈមមុខនឹងអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច ការមិនយកចិត្តទុកដាក់ និងប្រព្រឹត្តបទល្មើសទទួលបានសេវាការពារ និងការថែរក្សាក្នុងគ្រួសារ (ការគាំទ្រគ្រួសារ និងការគាំពារសង្គមផ្សេងទៀត) |
| **៣.ការពង្រឹង និងពង្រីកសេវាផ្សព្វផ្សាយ** | ៣. ការផ្លាស់ប្តូរនិយាមសង្គម (កម្រិតបឋម) | ៣. គ្រួសារ សាលារៀន និងសហគមន៍ នឹងថែទាំកុមារក្នុងបរិយាកាសប្រកបដោយសុវត្ថិភាព ហើយការចិញ្ចឹមកូនតាមបែបវិជ្ជមាននឹងត្រូវបានផ្តល់ជូនដល់ឪពុកម្តាយ និងអាណាព្យាបាល និងអ្នករស់នៅក្នុងសហគមន៍ទាំងអស់ |
| **៤.ការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ** | ៤.ដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ(CPIMS) | ៤. ព័ត៌មាន និងទិន្នន័យស្តីពីកិច្ចការពារកុមារត្រូវបានរួមបញ្ចូលឱ្យប្រទាក់ក្រឡាគ្នា និងងាយស្រួលប្រើប្រាស់សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ |
| **៥.ការបង្កើតយន្តការសម្របសម្រួល** | ៥.បង្កើតបានយន្តការសម្របសម្រួលវិស័យកិច្ចការពារកុមាររវាងក្រសួង ស.អ.យ និងក្រសួងមហាផ្ទៃ រួមទាំងដៃគូអភិវឌ្ឍន៍ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ៥.រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សម្របសម្រួលជាមួយគ្នាដើម្បីបង្កឱ្យមានកិច្ចសហការគ្នាល្អ និងការផ្តល់ការគាំទ្រគ្នាប្រកបដោយប្រសិទ្ធភាព ក្នុងការទប់ស្កាត់ និងការពារកុមារទៅតាមតម្រូវការរបស់ពួកគេ |

## លទ្ធផលរំពឹងទុកនៃវិស័យនេះ

ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ មានរយៈពេលប្រាំឆ្នាំ (២០២២-២០២៦)។ លទ្ធផលរំពឹងទុកសំខាន់ៗពីដំណើរការនេះមានដូចខាងក្រោម៖

- ភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់ក្រសួងសាមីកាន់តែប្រសើរឡើង ដែលនាំឈានទៅរកការពង្រឹងគណនេយ្យភាព និងសមត្ថភាពប្រព័ន្ធ
- ការសម្របសម្រួលដែលកាន់តែល្អ និងមានលក្ខណៈជាប្រព័ន្ធដែលបង្កលក្ខណៈឱ្យចំណាត់ការនានារបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល អាចតម្រឹមអាទិភាពរបស់ខ្លួនតាមផែនការនេះ។ ការធ្វើបែបនេះក៏នឹងជួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ ក្នុងការប្រើប្រាស់នូវធនធានមនុស្សតិចតួចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ បើមិនដូច្នេះទេ ធនធានមនុស្ស នឹងត្រូវបានអូសទាញទៅតាមសេចក្តីត្រូវការពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលនានាការរៀបចំ ចក្ខុវិស័យ គោលបំណងកម្មវិធី និងគោលដៅរួមនៅក្នុងចំណោមភាគីពាក់ព័ន្ធ ស្តីពីអាទិភាពជាយុទ្ធសាស្ត្រ និងការចំណាយ ដែលឈានទៅរកការអន្តរាគមន៍ដែលស៊ីសង្វាក់គ្នាសម្រាប់វិស័យ
- ការពង្រីកលំហរសារពើពន្ធ៖ ប្រសិនបើក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ អាចបង្កើតទឡ្ហីករណ៍នៃការរៀបចំផែនការឱ្យកាន់តែប្រសើរ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងលទ្ធផលកាន់តែល្អនៅក្រសួងទាំងពីរ នឹងមានលទ្ធភាពទទួលបានមូលនិធិគាំទ្រកាន់តែច្រើនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់កិច្ចការពារកុមារ
- ការសម្រេចបានលទ្ធផល និងវិសាលភាពនៃលទ្ធផល
- ការតាមដានត្រួតពិនិត្យតាមវិស័យ ការបង្កើតទឡ្ហីករណ៍ និងការកាត់បន្ថយរបាយការណ៍ជាន់គ្នា ផែនការមួយ របាយការណ៍មួយ
- និរន្តរភាព៖ ជួយគាំទ្ររាជរដ្ឋាភិបាលកម្ពុជាឱ្យសម្រេចបាននូវការផ្លាស់ប្តូរជាប្រព័ន្ធសម្រាប់រយៈពេលវែង
- ការពង្រឹងប្រព័ន្ធកិច្ចការពារកុមារ
- រួមចំណែកចំពោះការអនុវត្តអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅសហគមន៍ ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ
- រួមចំណែកចំពោះការអនុវត្តអនុក្រឹត្យលេខ ១៨២ ១៨៣ និង ១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាល ខណ្ឌ ក្រុង ស្រុក
- រួមចំណែកចំពោះយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់កម្ពុជាសម្រាប់ "ការផ្លាស់ប្តូរថ្មី" ដោយផ្តោតការយកចិត្តទុកដាក់លើ "មនុស្ស" សណ្តាប់ធ្នាប់សង្គម និងសន្តិភាព។ ការងារសង្គមមានការពាក់ព័ន្ធជាចម្បងជាមួយនឹងការជួយមនុស្ស ដោយធានានូវសុវត្ថិភាពនិងសុខុមាលភាព។
- រួមចំណែកចំពោះការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩

# ជំពូកទី ១

## សេចក្តីផ្តើម

### ១.១. សាវតា

កិច្ចការពារកុមារត្រូវបានកំណត់និយមន័យយ៉ាងទូលំទូលាយថាជាការបង្ការទប់ស្កាត់ និងការឆ្លើយតបចំពោះការរំលោភបំពានផ្លូវកាយ ការរំលោភបំពានផ្លូវចិត្ត ការរំលោភបំពានផ្លូវភេទ ការមិនអើពើ និងការកេងប្រវ័ញ្ច។ ប្រព័ន្ធកិច្ចការពារកុមារ សំដៅដល់គោលនយោបាយ កម្មវិធី សកម្មភាព រួមទាំងក្របខ័ណ្ឌគតិយុត្ត និងយន្តការដែលមានស្រាប់ ដែលត្រូវបានដំណើរការអនុវត្តដែលមានលក្ខណៈជាប្រព័ន្ធប្រទាក់ក្រឡាគ្នា ដើម្បីបង្ការទប់ស្កាត់ការអន្តរាគម ការផ្តល់សេវា និងការឆ្លើយតបដល់កុមារដែលកំពុងស្ថិតក្នុងហានិភ័យសេដ្ឋកិច្ច កុមាររងគ្រោះនិងងាយរងគ្រោះដែលបាន និងកំពុងទទួលរងនូវការជួញដូរ ការរំលោភបំពាន ការកេងប្រវ័ញ្ចផ្សេងៗ ការមិនអើពើ និងអំពើហិង្សាគ្រប់ទម្រង់។[1]

គោលនយោបាយថែទាំជំនួសចំពោះកុមារ និងគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការការពារកុមារ ប្រព័ន្ធកិច្ចការពារកុមារ មានសមាសធាតុជាចម្បងចំនួនបី គឺ៖ ១) ការបង្ការទប់ស្កាត់និងកិច្ចការពារ ២) អន្តរាគមន៍ និង ៣)ការផ្តល់សេវានិងការឆ្លើយតប។

យោងតាមអង្គការយូនីសេហ្វ (២០២១) ប្រព័ន្ធកិច្ចការពារកុមារ មានសមាសធាតុសំខាន់ៗចំនួនប្រាំពីរ រួមមាន៖

(១).ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ
(២).អភិបាលកិច្ច និងរចនាសម្ព័ន្ធសម្របសម្រួល
(៣).សេវាថែទាំបន្តបន្ទាប់
(៤).ស្តង់ដារអប្បបរមា និងយន្តការគ្រប់គ្រង
(៥).ធនធានមនុស្ស ហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធ
(៦).យន្តការសម្រាប់ការចូលរួមរបស់កុមារ និងការចូលរួមសហគមន៍
(៧).ប្រព័ន្ធត្រួតពិនិត្យ និងប្រមូលទិន្នន័យ

ប្រព័ន្ធការពារកុមារក៏រួមបញ្ចូលផងដែរនូវតួអង្គផ្សេងៗគ្នា ដូចជា កុមារ គ្រួសារ សហគមន៍ អ្នកដែលធ្វើការនៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងអន្តរជាតិ។ ប្រព័ន្ធកិច្ចការពារកុមារ ជួយដល់កុមារទទួលបានលទ្ធផលជាច្រើន។ មានសារៈសំខាន់ណាស់ក្នុងការទទួលស្គាល់ និងពង្រឹងទំនាក់ទំនងរវាងប្រព័ន្ធកិច្ចការពារកុមារ និងប្រព័ន្ធក្នុងវិស័យផ្សេងៗ ទៀត។ ការពង្រឹងនូវសមាសធាតុប្រព័ន្ធកិច្ចការពារកុមារ និងតួអង្គសំខាន់ៗទាំងនោះ ពិតជាមានសារៈសំខាន់ដើម្បីផ្តល់លទ្ធផលប្រកបដោយគុណភាពដល់កុមារ។ ភាពទាក់ទង និងពាក់ព័ន្ធរវាងវិស័យនានា មានសារៈសំខាន់ណាស់ ដើម្បីបង្កើតសេវាថែទាំជាបន្តបន្ទាប់ ជាពិសេសផ្នែកកិច្ចការពារកុមារ សុខុមាលភាពសង្គម និងវិស័យផ្សេងៗទៀត ដូចជា វិស័យអប់រំ សុខាភិបាល ការអនុវត្តច្បាប់ និងយុត្តិធម៌ ។ល។[2]

ប្រព័ន្ធកិច្ចការពារកុមារ ពីមុនផ្តោតការយកចិត្តទុកដាក់ទៅលើតែកុមារ និងគ្រួសាររបស់ពួកគេ ដែលបានរងគ្រោះ បច្ចុប្បន្ននេះក៏បានផ្តោតលើការបង្ការ និងទប់ស្កាត់កុមារ និងគ្រួសារពីការរងគ្រោះផងដែរ។ ការផ្លាស់ប្តូរនេះអាចជួយដោះស្រាយបញ្ហាកិច្ចការពារកុមារតាំងពីឫសគល់នៃបញ្ហា។

ប្រព័ន្ធកិច្ចការពារកុមារក៏គួរមានឥទ្ធិពលលើនិយាមសង្គមដែលមានលក្ខណៈអវិជ្ជមានចំពោះកុមារ និងពង្រឹងការអនុវត្តកិច្ចការពារកុមារនៅតាមសហគមន៍ផងដែរ (UNICEF Cambodia, 2016; Bromfield & Higgins, 2005)។ គួរកត់សម្គាល់ថា គ្រួសារនិងសហគមន៍ គឺជាចំណុចស្នូលនៃប្រព័ន្ធកិច្ចការពារកុមារ។ វិធានការណ៍ដែលតួអង្គទាំងឡាយ អនុវត្តមានភាពពាក់ព័ន្ធច្រើនដល់ការបំពេញមុខងារក្នុងការបង្កើនសមត្ថភាព និងកិច្ចខិតខំប្រឹងប្រែងរបស់ គ្រួសារ និងសហគមន៍ ដើម្បីជួយឱ្យកុមារ

១ គោលនយោបាយជាតិស្តីពីប្រព័ន្ធការពារកុមារ ឆ្នាំ ២០១៩ - ២០២៩
២. ពង្រឹងប្រព័ន្ធកិច្ចការពារកុមារ វិធីសាស្រ្តនៃការធ្វើអន្តរាគមន៍ដែលមានការវាស់វែង (អង្គការយូនីសេហ្វ ខែកញ្ញា ២០២១)

រស់នៅប្រកបដោយសុវត្ថិភាព។ បើទោះបីជាគួរមានអង្គភាពដែលកំណត់ ដោយច្បាប់ ដើម្បីគ្រប់គ្រងលើកិច្ចការពារកុមារជារួម ហើយមានអាណត្តិច្បាស់លាស់ក្តី ក៏ទំនួលខុសត្រូវចំពោះការកំណត់ រកបញ្ហា និងការបញ្ជូនបញ្ហា និងការទប់ស្កាត់ការរំលោភបំពានមានភាពប្រទាក់ក្រឡាជាមួយនឹងក្រសួង និងដៃគូអភិវឌ្ឍន៍ផ្សេងៗគ្នាផងដែរ។ ហេតុនេះចរិតប្រទាក់ក្រឡានៃកិច្ចការពារកុមារធ្វើឱ្យមានភាពចាំបាច់ក្នុងការធានានូវកិច្ចសហការអន្តរក្រសួង និងដៃគូអភិវឌ្ឍន៍ ក៏ប៉ុន្តែ នៅទីបំផុត រាជរដ្ឋាភិបាល គឺជាអ្នកមានគណនេយ្យភាពចំពោះសុវត្ថិភាព និងកិច្ចការពារកុមារគ្រប់រូប។

**ការគាំទ្រសម្រាប់កុមារអាចមានបីកម្រិត ដូចខាងក្រោម៖**

- **កម្រិតទី ១ ឬ កម្រិតបឋម** ៖ សំដៅដល់ការផ្តល់ការអប់រំ និងសេវាដទៃទៀត ជាលក្ខណៈទូទៅ ដែលគាំទ្រដល់ប្រជាជនទាំងមូល ដែលផ្តោតលើការការពារបញ្ហាជាមុន។
- **កម្រិតទី ២ ឬ កម្រិតមធ្យម** ៖ សំដៅដល់ការគាំទ្រគ្រួសារដែលកំពុងមានតម្រូវការជំនួយ ដើម្បីកាត់ បន្ថយហានិភ័យ ឬបញ្ហាដែលបានរកឃើញ និងទប់ស្កាត់ការវិវឌ្ឍទៅរកភាពធ្ងន់ធ្ងរ។
- **កម្រិតទី ៣ ឬ កម្រិតធ្ងន់** ៖ សំដៅដល់ការគាំទ្រកុមារដែលបាននិងកំពុងប្រឈម ឬរងគ្រោះ ឬមានការឈឺចាប់គួរឱ្យកត់សម្គាល់ ហើយត្រូវការសេវាកិច្ចការពារកុមារ ឬអន្តរាគមន៍ពីអ្នកជំនាញកិច្ចការពារកុមារ។

នៅមិនទាន់មាននិយមន័យច្បាស់លាស់ នៃ"ការបង្កការឈឺចាប់ដល់កុមារគួរឱ្យកត់សម្គាល់"ពាក់ព័ន្ធនឹងការ កំណត់ក្របខ័ណ្ឌទ្រឹស្តីខាងលើទៅតាមបរិបទ នៃប្រទេសកម្ពុជានៅពេលបច្ចុប្បន្ន ខណៈដែលនិយមន័យនេះកំពុងត្រូវបានកំណត់នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ។ ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារនេះ ផ្តោតទៅលើការបង្កើតប្រព័ន្ធស្នូលសម្រាប់កិច្ចការពារកុមារ។ បញ្ហាចម្បងមួយនៅក្នុងវិស័យកិច្ចការពារកុមារ គឺនៅខ្វះប្រព័ន្ធផ្លូវការដែលឆ្លើយតបនៅកម្រិតទី៣។ ចំណែកកម្រិតទី១ និងទី២ ក៏មានសារៈសំខាន់ផងដែរ ប៉ុន្តែកម្រិតទាំងពីរនេះបាន និងកំពុងអនុវត្តដោយក្រសួងស្ថាប័នជំនាញនីមួយៗ ដូចមានចែងនៅក្នុងផែនការសកម្មភាពរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ឆ្នាំ២០២១-២០២៥)។

ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ផ្តោតលើការប្រើប្រាស់ "អភិក្រមជាប្រព័ន្ធ" ក្នុងការរៀបចំយន្តការរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ដើម្បីមានការសម្របសម្រួល និងមានធនធានប្រសើរជាងមុន សម្រាប់ការផ្តល់សេវាកិច្ចការពារកុមារ ព្រមទាំងពង្រឹងសមត្ថភាពគ្រួសារ និងសហគមន៍ ក្នុងការផ្តល់ការចិញ្ចឹមបីបាច់ និងការថែទាំកុមារប្រកបដោយសុវត្ថិភាព។ ការធ្វើដូចនេះមានន័យថា កុមារដែលមានហានិភ័យ ឬកំពុងរងគ្រោះ នឹងទទួលបានការគាំទ្រស្របតាមតម្រូវការ និងបំពេញឧត្តមប្រយោជន៍របស់ពួកគេ តាមរយៈប្រព័ន្ធកិច្ចការពារកុមារពីអាជ្ញាធរមានសមត្ថកិច្ច ដែលនឹងអនុវត្តតាមបទដ្ឋាន នីតិវិធីប្រតិបត្តិសមស្រប អនុវត្តការគ្រប់គ្រងករណី និងបញ្ជូនករណីប្រកបដោយប្រសិទ្ធភាព និងសហការជាមួយដៃគូដើម្បីគ្រប់គ្រងករណី។

ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធសំខាន់ៗ ផែនការនេះនឹងផ្តោតលើទិដ្ឋភាពចំនួនប្រាំនៃកិច្ចការពារកុមារ ដូចខាងក្រោម៖

១).**ការរៀបចំលិខិតបទដ្ឋានគតិយុត្តិ និងពង្រឹងប្រព័ន្ធប្រតិបត្តិការ៖** ជារួម កិច្ចការនេះ រួមមាន ការពង្រឹងការអនុវត្តការងាររបស់ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ដែលជាអ្នកផ្តល់សេវាកិច្ចការពារកុមារចម្បង។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក៏ជាផ្នែកមួយនៃប្រព័ន្ធកិច្ចការពារកុមារផងដែរ ដូចមានចែងនៅក្នុងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួល បន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដែលតួនាទីរបស់ពួកគេមាននៅត្រឹមកម្រិតហានិភ័យទាប ដែលមិនត្រូវការអន្តរាគមន៍ផ្នែកកិច្ចការពារកុមារដោយត្រូវបញ្ជូនករណីកិច្ចការពារកុមារទៅកាន់ថ្នាក់ក្រុង ស្រុក ខណ្ឌ និងផ្តល់ការគាំទ្រដល់ពួកគេ។

២).**ការពង្រឹង និងពង្រីកសេវាបង្ការទប់ស្កាត់ និងសេវាគាំទ្រ៖** នៅពេលបច្ចុប្បន្ន សេវាបង្ការទប់ស្កាត់ត្រូវបានផ្តល់ជាបឋមដោយទាំងរាជរដ្ឋាភិបាល (ដូចជា កម្មវិធីឧបត្ថម្ភសាច់ប្រាក់) និងដោយដៃគូអភិវឌ្ឍន៍។ សេវាបង្ការ ទប់ស្កាត់ និងសេវាគាំទ្រ ចាំបាច់ត្រូវបានពង្រឹងនិងពង្រីកតាមរយៈសកម្មភាពចាំបាច់ជាច្រើន។

៣).**ការពង្រឹង និងពង្រីកសេវាផ្សព្វផ្សាយ៖** កិច្ចការនេះ រួមមាន ការលើកកម្ពស់ការអនុវត្តអភិក្រមសង្គមដែលវិជ្ជមានអំពីកិច្ចការពារកុមារនៅក្នុងសង្គម ដោយមានការបង្កើនការផ្សព្វផ្សាយយុទ្ធនាការគ្រួសាររឹងមាំ នៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT) និងយុទ្ធនាការផ្លាស់ប្តូរអាកប្បកិរិយាផ្សេងៗរួមទាំងដំណើរការយន្តការកិច្ចការពារកុមារតាមសហគមន៍។

**៤).ការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ ៖** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាន និងកំពុងដឹកនាំប្រតិបត្តិការប្រព័ន្ធគ្រប់គ្រងព័ត៌មានរួចហើយ ដោយបានបង្កើតក្រុមការងារប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដែលមានសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ។ ការងារដែលត្រូវពង្រឹងបន្ថែម គឺផ្ទាំងទិន្នន័យ (Dashboard) CPIMS និងប្រព័ន្ធប្រតិបត្តិការដែលផ្តល់ទិន្នន័យទៅ CPIMS បង្កើតប្រព័ន្ធឌីជីថលគ្រប់គ្រងករណីដែលផ្សារភ្ជាប់គ្នា។

**៥).ការបង្កើតយន្តការសម្របសម្រួល៖** វិស័យកិច្ចការពារកុមារនៅមានកង្វះខាតយន្តការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព។ នៅពេលបច្ចុប្បន្ន មាន "យន្តការដាច់ដោយឡែកពីគ្នា" និង "យន្តការតាមកម្មវិធីជាក់លាក់" ច្រើនពេក ប៉ុន្តែមិនមែនជាយន្តការសម្រាប់វិស័យនេះឡើយ។ ក្រុមការងាររួមនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នឹងត្រូវបានបង្កើតឡើងនៅក្រោមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ និងមានតួនាទីសម្របសម្រួលជាចម្បងនៅក្នុងការអនុវត្តផែនការនេះ។

រហូតមកដល់ពេលនេះ ការផ្តោតលើអភិក្រមតាមវិស័យ (sector approach) នៅក្នុងកិច្ចការពារកុមារនៅមានកម្រិតនៅឡើយ។ ដូចនេះ យើងត្រូវការជាចាំបាច់ក្នុងការរៀបចំផែនការអនុវត្តយុទ្ធសាស្ត្រក្របខ័ណ្ឌវិស័យនៅក្នុងកិច្ចការពារកុមាររួមមួយ ខណៈដែលផែនការនៅតាមក្រសួង ស្ថាប័ននានា ដូចជាវិស័យអប់រំ និងសុខាភិបាល ជាទូទៅ ផ្តោតការយកចិត្តទុកដាក់នៅក្នុងសាមីក្រសួងនីមួយៗ។ ឧទាហរណ៍ កុមារងាយរងគ្រោះដែលត្រូវបានកំណត់ឃើញនៅកម្រិតមូលដ្ឋាន ត្រូវបានរាយការណ៍ទៅកាន់អាជ្ញាធរមានសមត្ថកិច្ច និងក្រោយមកត្រូវបានបញ្ជូនទៅកាន់ស្ថាប័នដទៃទៀត (មានដូចជា មណ្ឌលសុខភាព មណ្ឌលស្តារនីតិសម្បទា ប្រព័ន្ធយុត្តិធម៌អនីតិជន) ដើម្បីទទួលបានសេវាគាំទ្រ។

## ១.២. ការផ្សារភ្ជាប់ជាមួយយុទ្ធសាស្ត្រ និងគោលនយោបាយជាតិ

ដោយសាររាជរដ្ឋាភិបាលកម្ពុជាមានយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ នេះគឺជាពេលវេលាដ៏សមស្រប ក្នុងការរៀបចំផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ដើម្បីឱ្យផែនការនេះអាចរួមចំណែកចំពោះគោលដៅរបស់ខ្លួន ជាពិសេស សម្រាប់ "ការផ្លាស់ប្តូរថ្មី" ដែលទាមទារនូវការពង្រឹងស្ថាប័នសាធារណៈទាំងអស់។ ជាពិសេស យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានចែងថា ការយកចិត្តទុកដាក់នឹងផ្តោតទៅលើ "មនុស្ស" និងការងារសង្គម គឺពាក់ព័ន្ធជាចម្បងជាមួយនឹងការជួយមនុស្ស។ លើសពីនេះ ការពង្រឹងសុវត្ថិភាព និងកិច្ចការពារ គឺជាបុរេលក្ខខណ្ឌសម្រាប់ការបង្កើតសន្តិភាព និងសណ្តាប់ធ្នាប់សង្គម ដែលជាទិដ្ឋភាពសំខាន់ពីរនៃយុទ្ធសាស្ត្រចតុកោណ។

ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារនេះ មានសង្គតភាពជាមួយគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ (ឆ្នាំ២០១៩-២០២៩) និងផែនការអនុវត្តនៃគោលនយោបាយនេះ ផែនការយុទ្ធសាស្ត្រសម្រាប់ការបណ្តុះបណ្តាលកម្លាំងសេវាសង្គមដោយផ្តោតការយកចិត្តទុកដាក់លើកិច្ចការពារកុមារ (ឆ្នាំ២០២១-២០២៥) គោលដៅ អភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជាត្រឹមឆ្នាំ២០៣០ ក្របខណ្ឌគោលនយោបាយជាតិស្តីពីកិច្ចគាំពារសង្គម ឆ្នាំ២០១៦-២០២៥ និងឯកសារពាក់ព័ន្ធដទៃទៀត។

ជារួម គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ២០២០ ផ្តោតលើសរសរស្តម្ភចំនួនបី i).ការបង្ការទប់ស្កាត់ និងកិច្ចការពារ ii).អន្តរាគមន៍ និង iii).ការផ្តល់សេវា និងការឆ្លើយតប ដែលទាមទារឱ្យមានការអនុវត្តជាពហុវិស័យក្នុងទំនាក់ទំនងជាប្រព័ន្ធប្រទាក់ក្រឡាគ្នា។ គោលនយោបាយនេះចែងថា កុមាររងគ្រោះនិងគ្រួសារ ត្រូវតែទទួលបានសេវាកិច្ចការពារកុមារដែលសមស្រប មានធនធានមនុស្ស និងមូលនិធិគ្រប់គ្រាន់។

ផែនការសកម្មភាព (ឆ្នាំ២០២១-២០២៥) នៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ផ្តល់សកម្មភាពលម្អិតដែលមានការប៉ាន់ប្រមាណថវិកាចំណាយសម្រាប់ក្រសួង និងអង្គភាពនានា ដើម្បីបំពេញតួនាទីរបស់ពួកគេ និងផ្តល់សេវាដោយឡែករបស់ពួកគេនៅក្នុងវិស័យកិច្ចការពារកុមារ។ ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ គឺផ្តោតលើតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ ដើម្បីផ្តល់សេវានៅថ្នាក់ក្រោមជាតិ ដែលនឹងរួមចំណែកចំពោះការអនុវត្តផែនការសកម្មភាព (ឆ្នាំ២០២១-២០២៥) នៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ។

កម្ពុជាមានផែនការចំនួនប្រាំបីស្ថិតក្នុងដំណាក់កាលអនុវត្តន៍ ឬនៅក្នុងដំណើរការនៃការរៀបចំ ដែលពាក់ព័ន្ធដោយផ្ទាល់ចំពោះកិច្ចការពារកុមារ (ក្នុងនោះ មានផែនការតែពីរប៉ុណ្ណោះដែលត្រូវបានប៉ាន់ប្រមាណថវិកាចំណាយ) និងផែនការយុទ្ធសាស្ត្រពីរ ដែលមានផលប៉ះពាល់លើកិច្ចការពារកុមារ។ ការរៀបចំផែនការថ្មីណាមួយគប្បីស្របជាមួយនឹងផែនការដែលមានស្រាប់ ហើយផែនការដែលមានស្រាប់គប្បីត្រូវបានពិនិត្យឡើងវិញទៅលើប្រសិទ្ធភាពរបស់ផែនការនោះ។ ផែនការទាំងនេះ រួមមាន ផែនការអនុវិស័យនៃអំពើហិង្សាលើកុមារ (ត្រូវបានប៉ាន់ប្រមាណថវិកាចំណាយ) យុត្តិធម៌អនីតិជន កំណែទម្រង់ការថែទាំកុមារ សកម្មភាពមីន ពលកម្មកុមារ (ត្រូវបានប៉ាន់ប្រមាណចំណាយ) និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក៏មានផែនការយុទ្ធសាស្ត្រថ្នាក់ស្ថាប័ន ដែលគួរពិចារណានៅពេលរៀបចំផែនការថ្មីពាក់ព័ន្ធនឹងកិច្ចការពារកុមារ។ ទោះបីជាយ៉ាងណាក្តី ផែនការប្រតិបត្តិនោះមានភាពខ្វះចន្លោះពាក់ព័ន្ធនឹងការផ្តោតការយកចិត្តទុកដាក់នៅថ្នាក់ក្រោមជាតិ។ ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ នេះនឹងមិនជំនួសផែនការជាក់លាក់ណាមួយខាងលើឡើយ ប៉ុន្តែនឹងបន្ថែមគុណតម្លៃ តាមរយៈការនាំយកអាទិភាពសំខាន់ៗឱ្យនៅជុំគ្នាមួយកន្លែង និងផ្តល់ក្របខ័ណ្ឌរួមមួយសម្រាប់ភាពប្រទាក់ក្រឡាគ្នា និងភាពបំពេញបន្ថែមឱ្យគ្នានៃសកម្មភាពនានា ដែលត្រូវបានអនុវត្ត ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ។

## ១.៣. ដំណើរការនៃការរៀបចំផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ

ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ នេះត្រូវបានរៀបចំឡើងជាមួយនឹងកិច្ចសហប្រតិបត្តិការពីអ្នកពាក់ព័ន្ធផ្នែកកិច្ចការពារកុមារ រួមមាន ក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ទីភ្នាក់ងារសហប្រជាជាតិ និងម្ចាស់ជំនួយនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត។

ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ ដោយមានការគាំទ្របច្ចេកទេសពី UNICEF បានផ្តួចផ្តើមកិច្ចពិភាក្សាដំបូងជាមួយអ្នកពាក់ព័ន្ធកាន់តែទូលំទូលាយ នៅឆ្នាំ២០១៩។ ដោយទទួលស្គាល់នូវគុណតម្លៃដែលផែនការតាមវិស័យនេះនឹងនាំមក ដើម្បីពង្រឹងបរិយាកាសកិច្ចការពារកុមារនៅកម្ពុជា ក្រសួងបានផ្តួចផ្តើមដំណើរការនៃការរៀបចំទស្សនទាន ការចែករំលែក ការកំណត់ចក្ខុវិស័យ ពីដំបូងជាមួយនឹងក្រសួង ស្ថាប័ន ដៃគូមិនមែនរដ្ឋាភិបាល និងដៃគូម្ចាស់ជំនួយ។

ដំណើរការនេះមានដូចតទៅ៖ ការរៀបចំ និងការចែករំលែកឯកសារទស្សនទាននៅឆ្នាំ២០១៩ ការកំណត់ចក្ខុវិស័យកិច្ចការពារកុមារជាមួយអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នៅឆ្នាំ២០២០ សិក្ខាសាលាទីមួយក្រោមកិច្ចសហការពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ ស្តីពីការរៀបចំផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ជាមួយតួអង្គនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីពិភាក្សាអំពីក្របខណ្ឌទស្សនទានជុំទីមួយ គោលបំណង និងចំណាត់ការអាទិភាពសំខាន់ៗដែលត្រូវបានស្នើ នៅឆ្នាំ២០២០។

នៅឆ្នាំ២០២០ ក្រុមការងារបច្ចេកទេសមួយ ដើម្បីត្រួតពិនិត្យដំណើរការជារួម នៃការរៀបចំផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារត្រូវក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បង្កើតឡើងក្រោមការដឹកនាំរបស់ឯកឧត្តម **នឹម ថូត** រដ្ឋលេខាធិការប្រចាំការ និងមានសមាសភាពពីក្រសួងមហាផ្ទៃ និងអង្គការដៃគូជាសមាជិក។ ដើម្បីទទួលបានធាតុចូលបន្ថែមសម្រាប់ដាក់ឆ្លងក្រុមការងារបច្ចេកទេសនេះ អង្គការ UNICEF គម្រោង FCF|REACT នៃអង្គការ Save the Children និង 3PC បានសហការរៀបចំធ្វើការពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនៅខែវិច្ឆិកា ហើយលទ្ធផលនៃការពិគ្រោះយោបល់នេះត្រូវបានចែករំលែកនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំលើកដំបូងរបស់ក្រុមការងារបច្ចេកទេសនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០។

កិច្ចប្រជុំនៃក្រុមការងារបច្ចេកទេសនេះ បានយល់ព្រមយ៉ាងទូលំទូលាយទៅលើគោលបំណងជាយុទ្ធសាស្ត្រចំណាត់ការ និងសកម្មភាពអាទិភាពកម្រិតខ្ពស់សម្រាប់គោលបំណងនីមួយៗ។ មកដល់ពេលបច្ចុប្បន្នមានអ្នកចូលរួម ជាច្រើននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងអ្នកតំណាងនៃបណ្តាញកុមារ និងយុវជន បានផ្តល់ធាតុចូលរបស់ពួកគេនៅក្នុងដំណើរការនេះ តាមរយៈព្រឹត្តិការណ៍ផ្សេងៗគ្នា ដែលបានពណ៌នាខាងលើ។

# ជំពូកទី ២

# ការវិភាគស្ថានភាព និងការពិនិត្យលើផែនការសំខាន់ៗ

## ២.១. ការវិភាគស្ថានភាព (វឌ្ឍនភាព បញ្ហា និងភាពខ្វះចន្លោះ)

កុមារគ្រប់រូបមានសិទ្ធិក្នុងការធំលូតលាស់នៅក្នុងបរិយាកាសប្រកបដោយសុវត្ថិភាព និងការចិញ្ចឹមបីបាច់គ្មានអំពីហិង្សា និងការកេងប្រវ័ញ្ច។ ដោយសារការគាំទ្រ និងការវិនិយោគមានការកើនឡើងសម្រាប់វិស័យកិច្ចការពារកុមារ កុមារនៅកម្ពុជាទទួលបានកិច្ចការពារកាន់តែប្រសើរជាងមុនតាមរយៈការពង្រឹងការអនុវត្តច្បាប់បទដ្ឋានគតិយុត្ត និងសេវាឆ្លើយតបនានារួមមាន ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ ។

ទន្ទឹមនឹងមានការវិនិយោគសម្រាប់កុមាររងាយរងគ្រោះ និងគ្រួសាររបស់ពួកគេ ដើម្បីទប់ស្កាត់អំពើហិង្សាលើកុមារ និងជំរុញការផ្តល់សេវាឆ្លើយតបបញ្ហារបស់កុមារនៅតែមាន និងត្រូវការសេវាដើម្បីគាំទ្រពួកគេ។ បញ្ហាកុមារនៅតែបន្តមានអាចបណ្តាលមកពីអវត្តមាន នៃច្បាប់ស្តីពីកិច្ចការពារកុមារ និងរចនាសម្ព័ន្ធច្បាស់លាស់សម្រាប់កិច្ចការពារកុមារ កង្វះខាតសេវាទប់ស្កាត់និងឆ្លើយតប (គុណភាព វិសាលភាព លទ្ធភាពក្នុងការទទួលបានសេវាគាំទ្រ) សម្រាប់កុមាររងាយរងគ្រោះនិងគ្រួសារនៅទូទាំងប្រទេស ចំនួនបុគ្គលិកសេវាសង្គមមិនគ្រប់គ្រាន់ សមត្ថភាពរបស់កម្លាំងសេវាសង្គមនៅមានកម្រិត ជំនាញនិងចំណេះដឹងអំពីអំពើហិង្សាលើកុមារនៅក្នុងចំណោមអ្នកផ្តល់សេវានៅមានកម្រិត និងកង្វះខាតចំណេះដឹងស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាននៅក្នុងចំណោមអ្នកថែទាំជាដើម។

មូលហេតុដទៃទៀត រួមមាន អំពើហិង្សាបន្តពីជំនាន់មួយទៅជំនាន់មួយទៀតទៅលើស្ត្រីនិងកុមារ ការទទួលយកនិយាមសង្គមដែលលើកកម្ពស់អំពើហិង្សាលើកុមារ និងការអនុវត្តវិន័យបែបហិង្សានៅផ្ទះ និងនៅសាលារៀន និយាមយេនឌ័របែបរើសអើង ការរើសអើងចំពោះកុមារដែលមានពិការភាព អាពាហ៍ពិពាហ៍ក្នុងវ័យកុមារនិងការមានផ្ទៃពោះក្នុងវ័យជំទង់ កង្វះខាតការសម្របសម្រួល និងកិច្ចសហការអន្តរវិស័យប្រព័ន្ធកិច្ចការពារកុមារទន់ខ្សោយគ្រប់កម្រិត ឬកង្វះការយល់ដឹងអំពីច្បាប់រួមទាំងច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងភាពក្រីក្រ រួមទាំងវិសមភាពផ្នែកសេដ្ឋកិច្ចសង្គមនៅតំបន់ជនបទនិងនៅតាមតំបន់ក្រីក្រក្នុងទីក្រុង។ លើសពីនេះក៏នៅមានកង្វះប្រព័ន្ធកិច្ចការពារកុមារមួយដែលប្រកបដោយការសម្របសម្រួលល្អ និងមានសមត្ថភាពក្នុងការកំណត់រកនិងឆ្លើយតបចំពោះករណីកិច្ចការពារកុមារ។

## ២.២. ការពិនិត្យលើផែនការពាក់ព័ន្ធសំខាន់ៗ

កម្ពុជាបាននិងកំពុងអនុវត្តផែនការ និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយបញ្ហាកិច្ចការពារកុមារ។ ផែនការនិងយុទ្ធសាស្ត្រពាក់ព័ន្ធសំខាន់ៗ រួមទាំងស្ថានភាពនៃការអនុវត្តឯកសារទាំងនេះមានដូចខាងក្រោម៖

**កំណែទម្រង់ការថែទាំកុមារ៖** សមិទ្ធផលធំបំផុតនៅក្នុងវិស័យកិច្ចការពារកុមារ គឺត្រូវបានចងក្រងនៅក្នុងវិស័យកំណែទម្រង់ការថែទាំកុមារ។ ផែនការសកម្មភាពពង្រឹងការថែទាំកុមារ និងសមាហរណកម្មកុមារចំនួន ៣០ភាគរយ ពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាពពីឆ្នាំ២០១៦-២០១៨ (ត្រូវបានពន្យារការអនុវត្តដល់ឆ្នាំ២០២០) បានធ្វើឱ្យមានផលប៉ះពាល់គួរឱ្យកត់សម្គាល់នៅក្នុងការធ្វើសមាហរណកម្មកុមារពីមណ្ឌលថែទាំកុមារ និងការលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារ។ អន្តរាគមន៍ច្រើនដំណាក់កាល ដែលកើតចេញពីផែនការសកម្មភាពប្រកបដោយមហិច្ឆិតាស្តីពីកំណែទម្រង់ការថែទាំកុមារ បានបង្កើតឱ្យមានឥទ្ធិពលរួមគ្នា ដែលនាំទៅរកការកាត់បន្ថយគួរឱ្យកត់សម្គាល់នូវការទុកដាក់កុមារនៅតាមមណ្ឌលថែទាំ និងការបង្កើតឱ្យមានការថែទាំកុមារនៅតាមគ្រួសារដែលជាជម្រើសល្អបំផុត។ ជារួម ក្រោយពីរបាយការណ៍ស្តីពីការកំណត់ទីតាំងកន្លែងថែទាំកុមារ បានផ្សព្វផ្សាយនៅឆ្នាំ២០១៦មក កម្ពុជាមានចំនួនមណ្ឌលថែទាំកុមារថយចុះអស់ ៤៣

ភាគរយ និងកាត់បន្ថយចំនួនកុមារនៅក្នុងមណ្ឌលថែទាំកុមារ បានចំនួន ៥៩ភាគរយ។ ចាប់តាំងពីឆ្នាំ២០១៦ គ្មានមណ្ឌលថែទាំកុមារថ្មីណាមួយបានទទួលការអនុម័តជាផ្លូវការពីរាជរដ្ឋាភិបាលឡើយ។ ចំណុចនេះបង្ហាញពីជោគជ័យនៃការប្ដេជ្ញាផ្នែកនយោបាយ និងអន្តរាគមន៍កម្មវិធីនៅក្នុងវិស័យ កំណែទម្រង់ការថែទាំកុមារ។

កាន់តែសំខាន់ជាងនេះ ថ្វីបើមានការរាតត្បាតជំងឺកូវីដ១៩ ក្ដី ប្រព័ន្ធគ្រប់គ្រងករណី Primero ត្រូវបានដាក់ឱ្យអនុវត្តនៅខែកក្កដា ឆ្នាំ២០២០ ដែលជួយសម្រួលដល់មន្ត្រីនៅថ្នាក់ក្រោមជាតិ ដើម្បីធ្វើការវាយតម្លៃទៅលើកុមារម្នាក់ៗដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ។ ការវាយតម្លៃនេះត្រូវបានពន្យារពេលជាយូរហើយ ហើយនេះគឺជាជំហានជោគជ័យដ៏សំខាន់មួយនៅក្នុងដំណើរការកំណែទម្រង់ការថែទាំកុមារ។ ថ្វីបើមានការកាត់បន្ថយចំនួនកុមារនៅក្នុងមណ្ឌលថែទាំគួរឱ្យកត់សម្គាល់យ៉ាងណាក្ដី ចំនួនកុមារដែលកំពុងរស់នៅក្នុងការថែទាំតាមមណ្ឌលជាក់ស្ដែងនៅតែមានចំនួនច្រើន (ចំនួន៦៧៧៨នាក់)។ កុមារទាំងនោះភាគច្រើន មានទាំងឪពុកម្ដាយនៅរស់ ឬយ៉ាងហោចណាស់មានឪពុក ឬម្ដាយ ដែលអាចសមាហរណកម្មទៅកាន់គ្រួសារ ឬសហគមន៍ពួកគេវិញបាន។ បច្ចុប្បន្ននេះពុំទាន់មានការរៀបចំ យន្តការបង្ការកុំឱ្យកុមារបែកពីគ្រួសារបានពេញលេញនៅឡើយទេ រីឯការទុកដាក់កុមារនៅក្នុងការថែទាំតាមគ្រួសារ ដូចជា ការថែទាំកុមារដោយឪពុកម្ដាយធម៌ចាំបាច់ត្រូវមានការពង្រឹងបន្ថែមទៀតផងដែរ។ កុមារមានពិការភាពមានហានិភ័យកាន់តែខ្ពស់ចំពោះការទុកដាក់នៅក្នុងមណ្ឌល។ រហូតមកដល់ពេលនេះ គឺជាលើកទីមួយហើយដែលកុមារទាំងអស់រស់នៅក្នុងមណ្ឌលថែទាំកុមារ ត្រូវបានកត់ត្រាតាមប្រព័ន្ធឌីជីថលនៅក្នុងប្រព័ន្ធគ្រប់គ្រងករណី Primero ដើម្បីជួយសម្រួលដល់ការតាមដាន ឱ្យកាន់តែជិតដល់និងការរៀបចំផែនការទុកដាក់កុមារអចិន្ត្រៃយ៍។ កុមារទាំងអស់ នេះត្រូវទទួលបានការយកចិត្តទុកដាក់ពីការរៀបចំផែនការករណី និងការគ្រប់គ្រងបន្ថែម។ ជាមួយគ្នានេះ ពួកគេត្រូវទទួលបាននូវការធានាថា គ្មានកុមារណាម្នាក់ត្រូវបានបំបែកចេញពីគ្រួសាររបស់ពួកគេ និងទុកដាក់នៅក្នុងមណ្ឌលថែទាំដោយមិនមានភាពចាំបាច់ឡើយ។

**ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១៖** ផែនការសកម្មភាពនេះកំពុងអនុវត្តនៅឡើយ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានធ្វើការវាយតម្លៃទូទាំងប្រទេសលើផែនការសកម្មភាពពាក់ព័ន្ធនឹងការទប់ស្កាត់អំពើហិង្សាលើកុមារ ដើម្បីវាស់វែងពីវិសាលភាព និងប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពក្នុងការដោះស្រាយបញ្ហាអំពើហិង្សាលើកុមារ។ លទ្ធផលនៃការវាយតម្លៃនេះនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការចង្អុលបង្ហាញទិសដៅសម្រាប់ការរៀបចំផែនការសកម្មភាពពាក់ព័ន្ធនឹងការទប់ស្កាត់អំពើហិង្សាលើកុមារ ឆ្នាំ២០២២-២០២៦ ដែលនឹងស្របគ្នាទៅនឹងផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារផងដែរ។ ទោះបីជាយ៉ាងក៏ដោយ បញ្ហាអំពើហិង្សាលើកុមារនៅតែបន្តកើតមាន។

**ផែនការអនុវត្តដំណាក់កាលទី១ ឆ្នាំ២០២១-២០២៥នៃគោលនយោបាយជាតិស្ដីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩៖** ផែនការសកម្មភាពនេះ ត្រូវបានដាក់ឱ្យអនុវត្តកាលពីខែកក្កដា ឆ្នាំ២០២១។ ផែនការសកម្មភាពនេះផ្ដោតការយកចិត្តទុកដាក់លើគោលបំណងជាយុទ្ធសាស្ត្រនិងអន្តរាគមន៍សំខាន់ៗ ដែលរួមបញ្ចូលនូវការប៉ាន់ស្មានថវិកា និងធនធានថវិកា ព្រមទាំងតួនាទី និងភារកិច្ចជាក់លាក់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ លើសពីនេះ ផែនការសកម្មភាពនេះក៏រួមបញ្ចូល ផែនការធនធានមនុស្ស និងការរៀបចំផែនការថវិកា ដើម្បីអនុវត្តក្របខណ្ឌ គោលនយោបាយជាតិ ដោយផ្អែកលើសរសរស្ដម្ភចំនួនបី៖ ១).ការទប់ស្កាត់និងកិច្ចការពារ ២).អន្តរាគមន៍ ការផ្ដល់សេវានិងសមាហរណកម្ម និង ៣).ថវិកានិងផែនការសម្រាប់ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ។

**ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិស្ដីពីច្បាប់យុត្តិធម៌អនីតិជន ឆ្នាំ២០១៨-២០២០ ត្រូវបានអនុម័តដោយក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅខែមីនា ឆ្នាំ២០១៨៖** ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិស្ដីពីច្បាប់យុត្តិធម៌អនីតិជន (JJLSOP) ឆ្នាំ២០១៨-២០២០ មានគោលបំណងផ្ដល់ផែនការអនុវត្តជាក់ស្ដែងសម្រាប់ដំណើរការយ៉ាងសំខាន់នៃការអនុវត្ត និងប្រតិបត្តិការជាបន្តបន្ទាប់ ដើម្បីកែលម្អជីវិតរបស់កុមារដែលទំនាស់នឹងច្បាប់។ ទោះបីជាយ៉ាងណាក្ដីមានកិច្ចការជាច្រើនទៀតដែលត្រូវអនុវត្តដើម្បីធានាថា យន្តការយុត្តិធម៌អនីតិជនទៅតាមបទដ្ឋានអន្តរជាតិ

ត្រូវបានរៀបចំឡើង។ កង្វះខាតជំនួយផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាពបានរួមចំណែកធ្វើឱ្យទំហំនៃការឃុំខ្លួនមុនពេលជម្រះក្តី និងការផ្តន្ទាទោសចំពោះជនល្មើសកម្រិតស្រាល អនីតិជន និងប្រជាជនងាយរងគ្រោះដទៃទៀតមានកម្រិតខ្ពស់។ ជនទាំងនេះមិនគួរស្ថិតនៅក្នុងមណ្ឌលឃុំឃាំង (មុនពេលជម្រះក្តី) ឡើយ ប្រសិនបើបទដ្ឋានយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានយកមកអនុវត្តប្រកបដោយប្រសិទ្ធភាព។ គោលនយោបាយស្តីពីជំនួយផ្លូវច្បាប់ត្រូវរៀបចំជាសេចក្តីព្រាងនៅឆ្នាំមុន ដោយទទួលបានធាតុចូលបច្ចេកទេសមួយចំនួនពីអង្គការ OHCHR គណៈមេធាវី និងសង្គមស៊ីវិល ប៉ុន្តែមិនទាន់ត្រូវបានអនុម័តនៅឡើយ។ គោលនយោបាយស្តីពីជំនួយផ្លូវច្បាប់នេះ គឺជាសមាសធាតុយ៉ាងសំខាន់ ដើម្បីគាំទ្រសិទ្ធិក្នុងការទទួលបានការជម្រះក្តីដោយយុត្តិធម៌ ជាពិសេសសម្រាប់អ្នកទាំងឡាយដែលមិនមានលទ្ធភាព ដើម្បីប្រើប្រាស់មេធាវីនៅក្នុងការការពារក្តីរបស់ពួកគេបាន។ ជម្រើសជំនួសឱ្យការឃុំខ្លួន (ឬហៅផងដែរថាជម្រើសជំនួស/សហគមន៍/ការកាត់ក្តីផ្តល់ដំណោះស្រាយក្រៅពីការឃុំខ្លួន) គឺជាទម្រង់ផ្សេងៗទៀតនៃការដាក់ពិន័យដែលតុលាការអាចដាក់ជំនួសឱ្យការជាប់ពន្ធនាគារ។ ប៉ុន្តែជម្រើសទាំងនេះមិនត្រូវបានយកមកប្រើប្រាស់បានគ្រប់គ្រាន់នៅឡើយទេនៅកម្ពុជា។

**ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ២០១៦-២០២៥៖** ផែនការនេះកំពុងស្ថិតនៅពាក់កណ្តាលអណត្តិនៃការអនុវត្ត។ ផែនការនេះបានលើកឡើងថា កុមារប្រហែលម្នាក់ក្នុងចំណោមកុមារប្រាំបួននាក់ដែលមានអាយុចន្លោះពី ៥ដល់ ១៧ឆ្នាំ បានចូលរួមនៅក្នុងពលកម្មកុមារ។ ក្នុងនោះពួកគេជាងពាក់កណ្តាលធ្វើការងារនៅក្នុងលក្ខខណ្ឌប្រកបដោយគ្រោះថ្នាក់និងមិនបានទៅរៀន។

**ផែនការយុទ្ធសាស្ត្រជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស (ឆ្នាំ២០១៩-២០២៣)៖** ក៏កំពុងស្ថិតនៅពាក់កណ្តាលអណត្តិនៃដំណើរប្រតិបត្តិការរបស់ខ្លួនផងដែរ ហើយបានរួមចំណែកក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងអំពើជួញដូរមនុស្ស។ ទោះបីជាយ៉ាងដូចនេះក្តីកង្វះទិន្នន័យគ្រប់ជ្រុងជ្រោយអំពីអំពើជួញដូរមនុស្សធ្វើឱ្យគេមិនអាចដឹងអំពីចំនួនច្បាស់លាស់នៃមនុស្ស រួមទាំងកុមារផង ដែលបានទទួលរងផលប៉ះពាល់ពីអំពើជួញដូរ។

កម្រិតអាពាហ៍ពិពាហ៍កុមារនៅតែស្ថិតក្នុងអត្រា ១៩ភាគរយ រីឯការមានផ្ទៃពោះក្នុងចំណោមស្ត្រីវ័យជំទង់អាយុ ១៩ឆ្នាំកំពុងបន្តកើនឡើង ជាពិសេស នៅក្នុងចំណោមស្ត្រីវ័យជំទង់ដែលក្រីក្រ បានរៀនត្រឹមបឋមសិក្សា និងរស់នៅតំបន់ជនបទ។

**ផែនការសកម្មភាព ដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (២០២១-២០២៥)** ដែលរៀបចំឡើងដោយដើម្បីអនុវត្តយន្តការឆ្លើយតបថ្នាក់ជាតិគំរូ រួមមាន៖ ១.គោលនយោបាយនិងអភិបាលកិច្ច ២.យុត្តិធម៌ព្រហ្មទណ្ឌ ៣.សេវាជនរងគ្រោះ ៤.សង្គម ៥.ឧស្សាហកម្ម ៦.ប្រព័ន្ធផ្សព្វផ្សាយទំនាក់ទំនងដែលបង្កើតឡើងដោយសេចក្តីថ្លែងការណ៍សកម្មភាពសកល (WePROTECT 2015) និងចូលរួមអនុវត្តសេចក្តីថ្លែងការណ៍របស់ប្រមុខរដ្ឋនៃប្រទេសជាសមាជិកអាស៊ានឆ្នាំ២០១៩។

ចំពោះដំណើរការប្រព័ន្ធព័ត៌មានកិច្ចការពារកុមារនិងប្រសិទ្ធភាពសម្រាប់ការប្រមូល ការវិភាគ និងការបកស្រាយទិន្នន័យសំខាន់ៗក្នុងប្រទេសកម្ពុជាក៏នៅមានកម្រិតក្នុងការផ្តល់ជាទឡ្ហីករណ៍បម្រើឱ្យប្រព័ន្ធកិច្ចការពារកុមារ។ បន្ថែមលើនេះ ការសិក្សា វាយតម្លៃរបស់ Coram បានបង្ហាញថា ការឆ្លើយតបចំពោះកិច្ចការពារកុមារមានការពឹងផ្អែកខ្លាំងទៅលើដៃគូរអភិវឌ្ឍន៍ ។

## រូបភាព ១៖ គោលដៅរយៈពេលវែងសម្រាប់ការរៀបចំផែនការវិស័យកិច្ចការពារកុមារនៅកម្ពុជា

### ត្រឹមឆ្នាំ ២០២៥

យើងនឹងមានក្រសួងដឹកនាំមួយ ដែលនឹងដាក់របៀបវារៈកិច្ចការពារកុមាររបស់ស្ថាប័នផ្សេងៗបញ្ចូលគ្នាឱ្យទៅជាផែនការយុទ្ធសាស្ត្ររួមមួយ ដែលដាក់ចេញនូវចក្ខុវិស័យរួម អាទិភាពសំខាន់ៗ យុទ្ធសាស្ត្រ និងក្របខណ្ឌត្រួតពិនិត្យតាមដានសម្រាប់កិច្ចការពារកុមារ។វានឹងក្លាយជាផែនការគោលដែលសម្រាប់ឱ្យម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលតម្រឹមការគាំទ្ររបស់ពួកគេតាម

**និង**

យើងនឹងសាកល្បងរៀបចំផែនការរួមនិងការអនុវត្តកម្មវិធីកិច្ចការពារកុមារដែលត្រូវបានជ្រើសរើស។

**លើសពីនេះ**

យើងនឹងដាក់ឱ្យមានការអនុវត្តសាកល្បងរួមគ្នាទៅលើការរៀបចំផែនការនិងការអនុវត្តកម្មវិធីកិច្ចការពារកុមារជាក់លាក់

**និង**

យើងនឹងមានរបាយការណ៍វឌ្ឍនភាពវិស័យរួមគ្នាមួយ

**ហើយ**

គ្រប់រាជធានី-ខេត្តទាំងអស់នឹងមានផែនការថ្នាក់រាជធានី-ខេត្ត។

### ត្រឹមឆ្នាំ ២០២៥

យើងនឹងមានកម្មវិធីកិច្ចការពារកុមារ និងធនធានភាគច្រើននៅក្នុងប្រទេស ឆ្លើយតបទៅនឹងផែនការវិស័យ

**និង**

យើងនឹងមានកម្មវិធី វិស័យរួមមួយ និងក្របខណ្ឌចំណាយមួយ

**និង**

គ្រប់រាជធានី-ខេត្តទាំងអស់នឹងមានផែនការថ្នាក់រាជធានី-ខេត្ត និងក្របខណ្ឌចំណាយ។

### ត្រឹមឆ្នាំ ២០៣០

យើងនឹងមានយន្តការអនុវត្តប្រកបដោយសុខដុមនីយកម្មនិងប្រើប្រាស់ប្រព័ន្ធនិងនីតិវិធីក្នុងប្រទេសរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តកម្មវិធីកិច្ចការពារកុមារភាគច្រើន។

---

យន្តការផ្តល់មូលនិធិនឹងមានលក្ខណៈចម្រុះគ្នារវាងប្រភេទគម្រោងនិងគម្រោងដាច់ដោយឡែកមានមូលនិធិរួមគ្នា

យន្តការផ្តល់មូលនិធិនឹងមានលក្ខណៈជាប្រភេទគម្រោងកាន់តែច្រើន និងមិនសូវមានលក្ខណៈដាច់ដោយឡែកការគាំទ្រថវិកាដែលត្រូវបានវិភាជមួយចំនួនមានមូលនិធិរួមគ្នា

យន្តការផ្តល់មូលនិធិនឹងប្រើប្រាស់ប្រព័ន្ធក្នុងប្រទេស ការគាំទ្រថវិកាវិស័យកាន់តែច្រើន ការវិភាជក្នុងកម្រិតកំណត់ គម្រោងដាច់ដោយឡែកតិចតួច

# ជំពូកទី ៣

# និដ្ឋភាពនៃផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ

គោលបំណងរួមនៃផែនការនេះ គឺដើម្បីកសាងប្រព័ន្ធកិច្ចការពារកុមារដែលមានលក្ខណៈរួមបញ្ចូលគ្នា និងសុខដុមនីយកម្មក្រោមការសម្របសម្រួលរបស់ក្រសួង ស.អ.យ និងក្រសួងមហាផ្ទៃ។ គោលបំណងនៃផែនការនេះ គឺដើម្បីផ្តល់ទិសដៅយុទ្ធសាស្ត្រកម្រិតខ្ពស់ទៅដល់ផែនការ និងសកម្មភាពពាក់ព័ន្ធនឹងកិច្ចការពារកុមារនៅក្នុងប្រទេសកម្ពុជា។ ផែនការនេះមិនមានបំណងជំនួសផែនការជាក់លាក់ ស្តីពីវិស័យនានានៃកិច្ចការពារកុមារឡើយ ដោយសារផែនការទាំងនោះនៅតែមានសារៈសំខាន់។ ទោះបីជាយ៉ាងណាក្តី ផែនការនេះបន្ថែមគុណតម្លៃ តាមរយៈការផ្តល់គោលដៅរួម និងសកម្មភាពនានាសម្រាប់វិស័យនេះ ដែលរួមបញ្ចូលអាទិភាពសំខាន់ៗទាំងអស់ឱ្យនៅមួយកន្លែង រួមទាំងការបញ្ចូលសមាសធាតុសំខាន់ៗនៃផែនការជាក់លាក់ដទៃទៀត និងពង្រឹងសមិទ្ធិកម្មនៃវិស័យនេះ តាមរយៈការបង្កើនសង្គតភាព និងភាពបំពេញបន្ថែមឱ្យគ្នានៃអន្តរាគមន៍នានាដើម្បីផ្តល់សេវាគាំទ្រ។

## ៣.១. ចក្ខុវិស័យ គោលបំណង និងគោលដៅ

**ចក្ខុវិស័យ៖** ធានាថាកុមារគ្រប់រូបទទួលបានសិទ្ធិជាមូលដ្ឋានសំខាន់ៗ ដូចជា សិទ្ធិរស់រានមានជីវិត និងការអភិវឌ្ឍ សិទ្ធិទទួលបានការអប់រំ សិទ្ធិទទួលបានការការពារ សិទ្ធិក្នុងការបញ្ចេញមតិ និងសិទ្ធិទទួលបានការរស់នៅ និងទំនាក់ទំនងជាមួយឪពុកម្តាយរបស់ពួកគេ ដូចមានចែងនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិដើម្បីកុមារ។

**គោលបំណង៖** រៀបចំប្រព័ន្ធកិច្ចការពារកុមារមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីបង្ការទប់ស្កាត់ អន្តរាគមន៍ និងការផ្តល់សេវាឆ្លើយតបនៅគ្រប់កម្រិតប្រកបដោយប្រសិទ្ធភាព ក្នុងការការពារកុមារគ្រប់ទម្រង់នៃការរំលោភបំពាននិងការអនុវត្តប្រកបដោយគ្រោះថ្នាក់។

**គោលដៅ៖** រៀបចំលិខិតបទដ្ឋានគតិយុត្ត និងពង្រឹងប្រព័ន្ធប្រតិបត្តិការក្នុងការផ្តល់សេវាបង្ការទប់ស្កាត់ឆ្លើយតប និងលើកកម្ពស់និយាមសង្គមតាមបែបវិជ្ជមាន ព្រមទាំងការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានស្តីពីកិច្ចការពារកុមារ និងការបង្កើតយន្តការសម្របសម្រួលផ្សេងៗទាក់ទងកិច្ចការពារកុមារ។

## ៣.២. គោលការណ៍សំខាន់ៗ

ផែនការនេះនឹងត្រូវអនុវត្តទៅតាមគោលការណ៍ជាមគ្គុទ្ទេសក៍ដូចខាងក្រោម៖

- **ឧត្តមប្រយោជន៍របស់កុមារ៖** គោលការណ៍ឧត្តមប្រយោជន៍របស់កុមារ គឺជាគោលការណ៍គ្រឹះមួយក្នុងចំណោមគោលការណ៍គ្រឹះនានានៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)។ ឧត្តមប្រយោជន៍របស់កុមារត្រូវតែជាការពិចារណាជាចម្បងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានឥទ្ធិពលលើកុមារ។ ឧត្តមប្រយោជន៍របស់កុមារត្រូវបានធានានៅក្នុងមាត្រា ៣ វាក្យខ័ណ្ឌទី១ នៃ CRC ដែលចែងថា៖ ...នៅក្នុងវិធានការទាំងអស់ពាក់ព័ន្ធនឹងកុមារ ទោះជាធ្វើឡើងដោយស្ថាប័នសាធារណៈ ឬឯកជនដែលទទួលបន្ទុកលើការងារសុខុមាលភាពសង្គម តុលាការ អាជ្ញាធររដ្ឋបាល ឬអង្គភាពនីតិបញ្ញត្តិផ្សេងទៀតក៏ដោយឧត្តមប្រយោជន៍របស់កុមារត្រូវតែជាការយកចិត្តទុកដាក់ចម្បង។ ការអនុវត្តយ៉ាងពេញលេញនូវទស្សនទាននៃឧត្តមប្រយោជន៍របស់កុមារ ទាមទារនូវការរៀបចំអភិក្រមដែលឈរលើមូលដ្ឋាននៃសិទ្ធិ និងការបង្កការចូលរួមរបស់តួអង្គទាំងអស់ ដើម្បីធានានូវសុចរិតភាពផ្នែករាងកាយ ចិត្តសាស្ត្រ សីលធម៌ និងស្មារតីគ្រប់ជ្រុងជ្រោយចំពោះកុមារ និងលើកកម្ពស់សេចក្តីថ្លៃថ្នូរ ការរស់រានមានជីវិត និងការអភិវឌ្ឍរបស់កុមារ ដូចមានចែងនៅក្នុងមាត្រា ៦ នៃ UNCRC។ ទស្សនទាននេះមានលក្ខណៈស្មុគស្មាញ

ហើយខ្លឹមសាររបស់វាត្រូវកំណត់ទៅតាមករណីជាក់ស្តែង។ ខ្លឹមសារ នៃទស្សនាទាននេះគប្បីមានការកែសម្រួល និងកំណត់និយមន័យទៅតាមស្ថានភាពជាក់លាក់របស់កុមារ ដោយពិចារណាលើបរិបទ ស្ថានភាព និងតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ។[៣]

- **សមធម៌៖** សមធម៌បានចាក់ឫសនៅក្នុងគោលការណ៍សកល ភាពគ្មានការរើសអើង បរិយាបន្ន និងការចូលរួម ដែលមានចែងនៅក្នុងមាត្រា ២ និងមាត្រា ១២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ អនុសញ្ញានេះធានានូវសិទ្ធិជាមូលដ្ឋានគ្រឹះរបស់កុមារគ្រប់រូប ដោយមិនគិតអំពីយេនឌ័រ ជាតិសាសន៍ ជំនឿសាសនា ប្រាក់ចំណូល រូបសម្បត្តិ ទីតាំងភូមិសាស្ត្រ ឬស្ថានភាពផ្សេងទៀតឡើយ។
- **ការពង្រឹងលើប្រព័ន្ធ៖** ដើម្បីឱ្យរចនាសម្ព័ន្ធនានារបស់ប្រទេស ត្រូវបានបង្កើតឡើង និងមាននិរន្តរភាព។ ហេតុនេះ ការយកចិត្តទុកដាក់នឹងត្រូវផ្តោតលើការបង្កើតប្រព័ន្ធ ឬយន្តការមួយជាជាងសកម្មភាពចំពោះកិច្ចនានា និងពង្រឹងយន្តការ ឬប្រព័ន្ធនានាដែលមានស្រាប់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- **កិច្ចសហការ និងភាពជាដៃគូ៖** ជាមួយដៃគូអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ សង្គមស៊ីវិល និងវិស័យឯកជន។ កម្ពុជានឹងបន្តផ្តោតលើភាពជាដៃគូទាំងនេះ ដើម្បីទទួលបានការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេស។ ជាពិសេស រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់តួនាទីយ៉ាងសំខាន់របស់ដៃគូអភិវឌ្ឍន៍នៅក្នុងវិស័យសុខុមាលភាពកុមារ និងសុខុមាលភាពសង្គម។ ទោះបីជាយ៉ាងណាក្តី និរន្តរភាពរបស់ដៃគូរអភិវឌ្ឍន៍មិនមានភាពប្រាកដប្រជានោះទេ ហើយពឹងផ្អែកច្រើនលើម្ចាស់ជំនួយ។ ប៉ុន្តែបើទោះបីជារាជរដ្ឋាភិបាលទទួលយកការងារដែលបច្ចុប្បន្នអនុវត្តដោយដៃគូអភិវឌ្ឍន៍ក្តី កិច្ចការនេះនឹងមិនកើតឡើងភ្លាមៗឡើយ។ ហេតុនេះ ផែនការអន្តរកាលមួយគប្បីត្រូវបានរៀបចំឡើងដែលមានបញ្ជាក់ពេលវេលាយ៉ាងច្បាស់លាស់។
- **បង្កើត និងប្រើប្រាស់ទទ្បីករណ៍** សម្រាប់ការរៀបចំផែនការដែលរឹងមាំ និងការគាំទ្រសេវាប្រកបដោយប្រសិទ្ធភាព។

## ៣.៣. កម្មវិធី គោលបំណង លទ្ធផលរំពឹងទុក លទ្ធផល និងសកម្មភាព

ដើម្បីសម្រេចបាននូវគោលបំណងជាយុទ្ធសាស្ត្រ ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ចាំបាច់ត្រូវអនុវត្តកម្មវិធីចំនួន៥ ដែលជាជំហានឈានទៅសម្រេចបាននូវលទ្ធផលឱ្យបានលឿនតាមដែលអាចធ្វើទៅបានដើម្បីសុវត្ថិភាពរបស់កុមារ។

### កម្មវិធីទី១៖ ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងពង្រឹងប្រព័ន្ធប្រតិបត្តិការ

**គោលបំណងកម្មវិធីទី១៖ ពង្រឹងប្រព័ន្ធច្បាប់ និងប្រតិបត្តិការសម្រាប់ការពារកុមារពីការរំលោភបំពានគ្រប់ប្រភេទ ជាពិសេសនៅពេលមានករណីកិច្ចការពារកុមារត្រូវបានរាយការណ៍ (កុមារទាំងអស់រួមទាំងជនរងគ្រោះសាក្សី និងជនល្មើស)**

**លទ្ធផលរំពឹងទុកកម្មវិធីទី១៖ មានប្រព័ន្ធកិច្ចការពារកុមារដោយមានកញ្ចប់ថវិកា ធនធានមនុស្ស និងមធ្យោបាយគ្រប់គ្រាន់ (ឧទាហរណ៍ សមត្ថភាពក្នុងការស៊ើបអង្កេត និងវាយតម្លៃ នៅពេលកុមារត្រូវបានចាត់ទុកថា ជាជនរងគ្រោះដោយអំពើហិង្សា ឬមានទំនាស់នឹងច្បាប់) និងជម្រើសថែទាំសមរម្យ ស្របតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ**

**លទ្ធផលទី១.១៖** ការផ្តល់អាជ្ញាប័ណ្ណ និងប្រព័ន្ធទទួលស្គាល់ជាផ្លូវការសម្រាប់កម្លាំងសេវាសង្គមកិច្ច

**សកម្មភាពសំខាន់ៗរួមមាន៖**

១.១.១. បង្កើតគោលការណ៍ណែនាំ ដើម្បីផ្តល់អាជ្ញាប័ណ្ណ និងការទទួលស្គាល់ដល់កម្លាំងសេវាសង្គមកិច្ច

១.១.២. រៀបចំប្រកាសសម្រាប់គណៈកម្មាធិការវាយតម្លៃ ដើម្បីផ្តល់អាជ្ញាប័ណ្ណ

១.១.៣. ផ្សព្វផ្សាយព័ត៌មានអំពីគោលបំណង និងសារៈសំខាន់នៃការផ្តល់អាជ្ញាប័ណ្ណដល់កម្លាំងសេវាសង្គម

៣ ឯកសារអនុវត្តជាក់ស្តែងសម្រាប់កិច្ចការពារកុមារ៖ គន្លឹះទី ១ - ការអនុវត្តគោលការណ៍ "ឧត្តមប្រយោជន៍របស់កុមារ" និង "ការមិនបង្កការឈឺចាប់" ដើម្បីគាំទ្រសមាហរណកម្មកុមារពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារនិងសហគមន៍

**លទ្ធផលទី១.២៖** ការពង្រឹងប្រព័ន្ធគ្រប់គ្រងករណី និងប្រព័ន្ធត្រួតពិនិត្យសម្រាប់អន្តរាគមន៍កិច្ចការពារកុមារ នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

**សកម្មភាពសំខាន់ៗរួមមាន៖**

១.២.១. ពង្រឹងការគ្រប់គ្រងករណីតាមកម្មវិធីសិក្សាសម្រាប់កម្លាំងសេវាសង្គមកិច្ចកម្រិត២ តាមរយៈការពង្រឹងសមត្ថភាពដល់ថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

១.២.២. ពង្រីកប្រព័ន្ធ Primero ដែលជាឧបករណ៍គ្រប់គ្រងករណីទៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌទាំងអស់ ដោយផ្សារភ្ជាប់ទៅនឹងប្រព័ន្ធគ្រប់គ្រងករណីអូស្កា (OSCaR) និងឧបករណ៍គ្រប់គ្រងករណីផ្សេងទៀតដែលអង្គការក្រៅរដ្ឋាភិបាលកំពុងប្រើប្រាស់

១.២.៣. បង្កើត និងដំណើរការប្រព័ន្ធត្រួតពិនិត្យសម្រាប់ការគ្រប់គ្រងករណីលើករណីកិច្ចការពារកុមារដល់មន្ត្រីរាជការ និងដៃគូអភិវឌ្ឍន៍ ដោយមានការសម្របសម្រួលជាមួយអ្នកជំនាញពីស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដោយរួមទាំងមន្ទីរសង្គមកិច្ចជាអ្នកផ្តល់ការត្រួតពិនិត្យផ្នែកបច្ចេកទេស និងការគាំទ្រ

**លទ្ធផលទី១.៣៖** ការរៀបចំបទដ្ឋាននីតិវិធីប្រតិបត្តិស្តីពីកិច្ចការពារកុមារ រួមទាំងក្របខ័ណ្ឌធានាពីគុណភាពស្តង់ដារអប្បបរមា និងនីតិវិធីត្រួតពិនិត្យនិងតាមដាន

**សកម្មភាពសំខាន់ៗរួមមាន៖**

១.៣.១. បង្កើតបទដ្ឋាននីតិវិធីប្រតិបត្តិស្តីពីកិច្ចការពារកុមារ (SOP) ពាក់ព័ន្ធនឹងកិច្ចការពារកុមារ

១.៣.២. កសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធសំខាន់ៗ ដែលបានកំណត់ដោយបទដ្ឋាននីតិវិធីប្រតិបត្តិស្តីពីកិច្ចការពារកុមារ (SOP)

១.៣.៣. បង្កើតតារាងលំហូរការងារថ្នាក់ក្រោមជាតិច្បាស់លាស់ និងការកំណត់អត្តសញ្ញាណ រួមទាំងរចនាសម្ព័ន្ធបញ្ជូនបន្ត

១.៣.៤. ធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គម ដោយបន្សុីគ្នានឹងសូចនាករដែលមានស្រាប់ទាក់ទងកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់

**លទ្ធផលទី១.៤៖** ការកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការរៀបចំផែនការកិច្ចការពារកុមារនិងថវិកា

**សកម្មភាពសំខាន់ៗរួមមាន៖**

១.៤.១. កៀរគរថវិកាកិច្ចការពារកុមារ និងសមត្ថភាពរៀបចំផែនការសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដោយផ្អែកលើគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ និងសៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់ ឃុំ សង្កាត់

១.៤.២. ពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ឃុំ សង្កាត់ លើការគ្រប់គ្រងករណីតាមកម្មវិធីសិក្សាសម្រាប់កម្លាំងសេវាសង្គមកិច្ចកម្រិត៣

**លទ្ធផលទី១.៥៖** ការរៀបចំផែនការប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅថ្នាក់ក្រោមជាតិ

**សកម្មភាពសំខាន់ៗរួមមាន៖**

១.៥.១. **ជំរុញការអនុវត្ត** ផែនការប្រតិបត្តិថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ស្តីពីកិច្ចការពារកុមារ

១.៥.២. បង្កើតទឡ្ហីករសម្រាប់វិនិយោគលើកម្លាំងសេវាសង្គម និងការផ្តល់ថវិកាដល់ការអនុវត្តផែនការកិច្ចការពារកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**លទ្ធផលទី១.៦៖** ការបង្កើតការកំណត់អត្តសញ្ញាណ ការប៉ាន់ប្រមាណ ការបញ្ជូន និងយន្តការរាយការណ៍អំពីករណីកិច្ចការពារកុមារកម្រិតធ្ងន់នៅក្នុងសហគមន៍

**សកម្មភាពសំខាន់ៗរួមមាន៖**

១.៦.១. ធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គម និងពង្រឹងយន្តការរាយការណ៍ដែលមានស្រាប់នៅថ្នាក់ឃុំ សង្កាត់
១.៦.២. ផ្តល់នូវការកសាងសមត្ថភាពដល់ គ.ក.ស.ក, គ.ក.ន.ក អ្នកស្ម័គ្រចិត្តសង្គមកិច្ចក្នុងសហគមន៍យន្តការកិច្ចការពារកុមារក្នុងសហគមន៍អំពីរបៀបរាយការណ៍ កំណត់អត្តសញ្ញាណ និងបញ្ជូនករណីកិច្ចការពារកុមារ យោងតាមសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ (SOP)
១.៦.៣. បង្កើតបណ្តាញរាយការណ៍ពិសេសតាមប្រព័ន្ធអ៊ិនធឺណិត នៅក្នុងក្រសួង ស.អ.យ និងពង្រឹងបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ និងបណ្តាញទូរស័ព្ទជំនួយកុមាររបស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមក

**លទ្ធផលទី១.៧៖** ការបង្កើត និងអនុវត្តគោលនយោបាយ/គោលការណ៍ណែនាំស្តីពីការគាំទ្រដល់គ្រួសារ
**សកម្មភាពសំខាន់ៗរួមមាន៖**
១.៧.១. ធ្វើផែនទីថ្នាក់ជាតិស្តីពីសេវាកម្មគាំទ្រគ្រួសារដែលមានស្រាប់
១.៧.២. បង្កើត និងអនុវត្តគោលនយោបាយ ឬគោលការណ៍ណែនាំស្តីពីការគាំទ្រដល់គ្រួសារ ជាលក្ខណៈស្តង់ដារជាតិ ដោយមានផែនការត្រួតពិនិត្យ និងវាយតម្លៃច្បាស់លាស់ ក្នុងការពិគ្រោះយោបល់ជាមួយ អ្នកពាក់ព័ន្ធ
១.៧.៣. ផ្សារភ្ជាប់ការអនុវត្ត និងធនធានពីកញ្ចប់កិច្ចការគាំពារសង្គមជាមួយនឹងគោលនយោបាយ ឬគោលការណ៍ណែនាំស្តីពីការគាំទ្រដល់គ្រួសារ

**លទ្ធផលទី១.៨៖** ការបង្កើតក្រមសីលធម៌សម្រាប់កម្លាំងសេវាសង្គម (SSWF) និងសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គម និងបណ្តុះបណ្តាល
**សកម្មភាពសំខាន់ៗរួមមាន៖**
១.៨.១. រៀបចំអនុក្រឹត្យស្តីពីក្រមសីលធម៌សម្រាប់កម្លាំងសេវាសង្គម និងបណ្តុះបណ្តាល
១.៨.២. រៀបចំក្រមសីលធម៌សម្រាប់កិច្ចការពារកុមារ
១.៨.៣. រៀបចំឯកសារបណ្តុះបណ្តាលស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងការងារសង្គម និងធ្វើការបណ្តុះបណ្តាល

**លទ្ធផលទី១.៩ ៖** ការពង្រឹងសេវាថែទាំ និងសមាហរណកម្មទៅក្នុងគ្រួសារនិងសហគមន៍
**សកម្មភាពសំខាន់ៗរួមមាន៖**
១.៩.១. បន្តរៀបចំសៀវភៅណែនាំស្តីពីនីតិវិធីអនុវត្តមុខងារនៃវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសម្រាប់មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច អ្នកអាជីពសង្គមកិច្ចរងក្រុង ស្រុក ខណ្ឌ
១.៩.២. ពង្រឹងការតាមដានត្រួតពិនិត្យ និងគាំទ្របច្ចេកទេសចំពោះករណីកុមាររងគ្រោះនិងងាយរងគ្រោះ
១.៩.៣. ពង្រឹងការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នីមួយៗ ពាក់ព័ន្ធនឹងកិច្ចការពារកុមារ
១.៩.៤. បង្កើនការបញ្ជូនករណីកិច្ចការពារកុមារពីឃុំ សង្កាត់ ទៅក្រុង ស្រុក ខណ្ឌ និងផ្តល់សេវាដល់កុមារ និងគ្រួសារដែលរងគ្រោះនិងងាយរងគ្រោះ
១.៩.៥. បង្កើនចំនួនបុគ្គលិកសង្គមកិច្ចនៅថ្នាក់ក្រុង ស្រុក ខណ្ឌ តាមរយៈការជ្រើសរើសថ្មី ឬការតែងតាំងមន្ត្រីរាជការដែលមានស្រាប់

**លទ្ធផលទី១.១០៖** ការបង្កើត និងអនុវត្តសាកល្បងបទដ្ឋានអប្បបរមា នៃសេវាកិច្ចការពារកុមារនៅតាមក្រុង ស្រុក ខណ្ឌនីមួយៗ (បទដ្ឋាននីតិវិធីប្រតិបត្តិស្តីពីកិច្ចការពារកុមារ)
**សកម្មភាពសំខាន់ៗរួមមាន៖**
១.១០.១. បង្កើតបទដ្ឋានអប្បរមានៃសេវាកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលផ្តោតលើបទដ្ឋាននីតិវិធីប្រតិបត្តិស្តីពីកិច្ចការពារកុមារ

១.១០.២. អនុវត្តសាកល្បងបទដ្ឋានអប្បបរមា នៃសេវាកិច្ចការពារកុមារ សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ មួយចំនួន
១.១០.៣. ធ្វើការវាយតម្លៃទៅលើលទ្ធផលនៃការអនុវត្តបទដ្ឋានអប្បបរមានៃសេវាកិច្ចការពារកុមារ និងពង្រីកឱ្យបានគ្រប់ រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស

**លទ្ធផលទី១.១១៖** ការបង្កើតរបាយការណ៍ជាក់លាក់ និងមធ្យោបាយបញ្ជូន
**សកម្មភាពសំខាន់ៗរួមមាន៖**
១.១១.១. វិភាគសេវាសាធារណៈ និងទីភ្នាក់ងារដែលមានកាតព្វកិច្ចទទួលបន្ទុកក្នុងការរាយការណ៍
១.១១.២. សម្របសម្រួលជាមួយបណ្តាញប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ និងប្រព័ន្ធជំនួយដល់កុមារដើម្បីបង្កើតជាមធ្យោបាយច្បាស់លាស់ ក្នុងការបញ្ជូនករណីដល់អាជ្ញាធរផ្អែកលើបទដ្ឋាននីតិវិធីប្រតិបត្តិ (SOP)

## កម្មវិធីទី២៖ ការពង្រឹង និងពង្រីកសេវាគោលដៅក្នុងការបង្ការទប់ស្កាត់ និងសេវាគាំទ្រ

**គោលបំណងកម្មវិធីទី២៖ ផ្តល់សេវាទប់ស្កាត់ និងបង្ការសម្រាប់គ្រួសារគោលដៅដែលមានតម្រូវការ**
**លទ្ធផលរំពឹងទុកកម្មវិធីទី២៖ កុមារ និងគ្រួសារដែលប្រឈមមុខនឹងអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច ការមិនអើពើ និងការប្រព្រឹត្តបទល្មើស ទទួលបានសេវាកម្មការពារនិងការថែរក្សាក្នុងគ្រួសារ (ការគាំទ្រគ្រួសារនិងការគាំពារសង្គមផ្សេងទៀត)**

**លទ្ធផលទី២.១៖** ការពង្រឹង និងការពង្រីកការសម្របសម្រួលសេវាបង្ការទប់ស្កាត់តាមសហគមន៍សម្រាប់គ្រួសារ ដែលមានកុមារងាយរងគ្រោះ និងងាយរងគ្រោះ
**សកម្មភាពសំខាន់ៗរួមមាន៖**
២.១.១. កំណត់អត្តសញ្ញាណកុមារដែលរងគ្រោះនិងងាយរងគ្រោះ និងតម្រូវការរបស់ពួកគេទៅតាមអាយុ និងភេទដើម្បីងាយស្រួលផ្តល់សេវាគាំទ្រ
២.១.២. ពង្រឹងការត្រួតពិនិត្យតាមដានការអនុវត្តប្រកាសស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ ព្រមទាំងគោលនយោបាយ និងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ
២.១.៣. លើកកម្ពស់ការទុកដាក់កុមារជាអចិន្ត្រៃយ៍ រាប់បញ្ចូលទាំងការសុំកូនក្នុងប្រទេស
២.១.៤. ផ្តល់សេវាដើម្បីបង្ការ និងទប់ស្កាត់កុមារដែលងាយរងគ្រោះក្នុងការបែកចេញពីគ្រួសារ
២.១.៥. បង្កើត និងអនុវត្តយន្តការត្រួតពិនិត្យសម្រាប់អ្នកថែទាំដែលជាឪពុកម្តាយធម៌ សាច់ញាតិ និងអ្នកផ្តល់សេវាសុំកូន យោងតាមគោលនយោបាយ និងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ
២.១.៦. ផ្តល់នូវបណ្តាញសុវត្ថិភាព (ការគាំទ្រជាសាច់ប្រាក់ និងសេវាគាំពារសង្គមផ្សេងទៀត តាមរយៈរាជរដ្ឋាភិបាល និងការកៀរគរធនធាននានាមកពីដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការមិនមែន រដ្ឋាភិបាល)
២.១.៧. ផ្តល់ការពង្រឹងសេដ្ឋកិច្ចដល់គ្រួសារ ដោយផ្តោតលើគ្រួសារគោលដៅ ដែលមានកុមារងាយរងគ្រោះ
២.១.៨. ផ្តល់ការគាំទ្រឪពុកម្តាយធម៌ និងសាច់ញាតិ ផ្សារភ្ជាប់ទៅការគាំទ្រការគាំពារសង្គម
២.១.៩. ផ្សារភ្ជាប់ប្រព័ន្ធគ្រប់គ្រងករណី Primero និងសេចក្តីព្រាងអនុក្រឹត្យ ដើម្បីគាំទ្រដល់ប្រជាជនដែលងាយរងគ្រោះដោយរួមបញ្ចូលទាំងការគាំទ្រដល់គ្រួសារដែលមានកុមារងាយរងគ្រោះ

**លទ្ធផលទី២.២៖** ការពង្រឹងការថែរក្សាកុមារក្នុងគ្រួសារ
**សកម្មភាពសំខាន់ៗរួមមាន៖**
២.២.១. បន្តអនុវត្តសៀវភៅណែនាំសម្រាប់ គ.ក.ន.ក ដើម្បីធ្វើឱ្យប្រសើរឡើងនូវការថែទាំកុមារ និងការវិលត្រឡប់របស់ពួកគេប្រកបដោយសុវត្ថិភាព

២.២.២. ពិនិត្យឡើងវិញនូវឯកសារបណ្តុះបណ្តាលការថែរក្សាកុមារក្នុងគ្រួសារដែលមានស្រាប់ និងកំពុងអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល សហការជាមួយក្រសួង ស.អ.យ និងដាក់ឱ្យប្រើប្រាស់

២.២.៣. កំណត់អត្តសញ្ញាណជនរងគ្រោះ និងបញ្ជូនបន្តទៅរកសេវាសង្គមផ្សេងៗ ដែលចាំបាច់សម្រាប់គ្រួសារ និងកុមារដែលអនុលោមទៅតាមកម្មវិធីផ្ទេរសាច់ប្រាក់ដែលកំពុងអនុវត្តដោយក្រសួង ស.អ.យ

**លទ្ធផលទី២.៣៖** ការផ្តល់សេវាដល់កុមារដែលទំនាស់នឹងច្បាប់ និងកុមារដែលតាមម្តាយនៅក្នុពន្ធនាគារ

**សកម្មភាពសំខាន់ៗរួមមាន៖**

២.៣.១. ធ្វើការប៉ាន់ប្រមាណស្ថានភាពកុមារដែលកំពុងរស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ

២.៣.២. ផ្តល់ការគាំទ្រផ្នែកគ្រប់គ្រងករណីដល់កុមារដែលបានកំណត់អត្តសញ្ញាណ រួមទាំងធ្វើសមាហរណកម្ម ទៅថែទាំក្នុងគ្រួសារ ឬសហគមន៍វិញបើអាចធ្វើទៅបាន

**លទ្ធផលទី២.៤៖** ការអភិវឌ្ឍជំនាញ និងកសាងសមត្ថភាពរបស់កម្លាំងសេវាសង្គម(SSWF) ក្នុងការផ្តល់សេវាកិច្ចការពារកុមារ (កម្រិតទី២ និងទី៣ នៃផែនការយុទ្ធសាស្ត្របណ្តុះបណ្តាលសេវាសង្គម)

**សកម្មភាពសំខាន់ៗរួមមាន៖**

២.៤.១. បង្កើតវគ្គបណ្តុះបណ្តាល និងយុទ្ធសាស្ត្រជំនាញឯកទេស (ផែនការយុទ្ធសាស្ត្របណ្តុះបណ្តាលសេវាសង្គម) និងកម្មវិធីសម្រាប់បង្កើនសមត្ថភាពគ្រប់លំដាប់ថ្នាក់ (ការបណ្តុះបណ្តាល រួមទាំងការអប់រំក្នុងប្រព័ន្ធជាផ្លូវការ)

២.៤.២. កសាងសមត្ថភាពផ្នែកតាមយុទ្ធសាស្ត្រនិងកម្មវិធីខាងលើ មុននិងអំឡុងពេលផ្តល់សេវា

២.៤.៣. បង្កើតការងារសម្រាប់មន្ត្រីរាជការដែលមានស្រាប់ពីក្រសួង ស.អ.យ និងក្រសួងមហាផ្ទៃ និស្សិតបញ្ចប់ការសិក្សាពីវិទ្យាស្ថានជាតិសង្គមកិច្ច សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យដទៃផ្សេងទៀត ដើម្បីក្លាយជាមន្ត្រីសាធារណៈដោយផ្អែកលើយុទ្ធសាស្ត្រជាតិស្តីពីកម្លាំងសេវាសង្គម

២.៤.៤. ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីអង្គការសុវត្ថិភាពកុមារដល់គ្រប់អ្នកធ្វើការងារពាក់ព័ន្ធនឹងកិច្ចការពារកុមារ

**លទ្ធផលទី២.៥៖** ការពង្រឹងសេវាថែទាំ និងសមាហរណកម្មកុមារទៅក្នុងគ្រួសារ និងសហគមន៍

**សកម្មភាពសំខាន់ៗរួមមាន៖**

២.៥.១. ជំរុញការអនុវត្តគោលការណ៍ណែនាំស្តីពីការធ្វើសមាហរណកម្មកុមារ ការបង្វែរកន្លែងថែទាំ និងការបិទកន្លែងថែទាំកុមារ

២.៥.២. ពិនិត្យឡើងវិញលើគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ឱ្យស្របតាមគោលការណ៍ ណែនាំសម្រាប់ការថែទាំជំនួសចំពោះកុមាររបស់អង្គការសហប្រជាជាតិ និងស្របតាមបរិបទកម្ពុជានាពេលបច្ចុប្បន្ន

២.៥.៣. រៀបចំផែនការករណីសម្រាប់កុមារទាំងអស់ដែលកំពុងស្នាក់នៅក្នុងមណ្ឌល (គ្រប់ករណីទាំងអស់ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងករណី Primero) និងផ្តល់សេវាសមាហរណកម្ម

២.៥.៤. សហការជាមួយមណ្ឌលថែទាំកុមារ ដែលមានបំណងធ្វើការបង្វែរកម្មវិធីការថែទាំកុមារក្នុងមណ្ឌលទៅជាការថែទាំតាមបែបសហគមន៍ ឬបិទមណ្ឌលថែទាំ

២.៥.៥. ពង្រឹង និងពង្រីកការអនុវត្តកម្មវិធីការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ និងការសុំកូន (ក្នុងប្រទេស និងក្រៅប្រទេស) រួមទាំងកុមារដែលមានពិការភាព

២.៥.៦. ពង្រឹងការថែទាំកុមារនៅតាមផ្ទះស្នាក់នៅជាក្រុម

២.៥.៧. ត្រៀម និងបន្សាំកុមារអំពីការរស់នៅក្នុងសហគមន៍មុនពេលចាកចេញពីមណ្ឌលថែទាំ

២.៥.៨. បន្តតាមដាន និងផ្តល់ការគាំទ្រកុមារដែលចាកចេញពីមណ្ឌលថែទាំ

**លទ្ធផលទី២.៦៖** ប្រតិបត្តិការកិច្ចការពារកុមារក្នុងស្ថានភាពគ្រោះអាសន្ន

**សកម្មភាពសំខាន់ៗរួមមាន៖**

២.៦.១. អនុវត្ត និងធ្វើបច្ចុប្បន្នភាពផែនការកិច្ចការពារកុមារក្នុងគ្រាអាសន្នរបស់ក្រសួង

២.៦.២. ផ្តល់ការកសាងសមត្ថភាពដល់អ្នកផ្តល់សេវា ដែលពាក់ព័ន្ធទៅនឹងការងារកិច្ចការពារកុមារអំពីស្តង់ដារអប្បបរមានៃការងារកិច្ចការពារកុមារ

## កម្មវិធីទី៣៖ ការពង្រឹង និងពង្រីកសេវាផ្សព្វផ្សាយ

**គោលបំណងកម្មវិធីទី៣៖ លើកកម្ពស់និយាមសង្គមដែលវិជ្ជមាន**

**លទ្ធផលរំពឹងទុកកម្មវិធីទី៣៖ គ្រួសារ សាលារៀន និងសហគមន៍ ថែទាំកុមារក្នុងបរិយាកាសប្រកបដោយសុវត្ថិភាព តាមរបៀបនៃការចិញ្ចឹមកូនតាមបែបវិជ្ជមានដែលបានផ្តល់ជូនដល់ឪពុកម្តាយ អ្នកថែទាំ និងសហគមន៍ទាំងអស់**

**លទ្ធផលទី៣.១៖** ការបង្កើនការផ្សព្វផ្សាយយុទ្ធនាការគ្រួសាររឹងមាំ នៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT) និងយុទ្ធនាការផ្លាស់ប្តូរអាកប្បកិរិយាផ្សេងៗ

**សកម្មភាពសំខាន់ៗរួមមាន៖**

៣.១.១. បន្តអនុវត្តយុទ្ធនាការគ្រួសាររឹងមាំនៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT)

៣.១.២. បញ្ចូលបញ្ហានៃអ្នកស្រឡាញ់ភេទដូចគ្នា និងការរើសអើងយេនឌ័រទៅក្នុងយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT)

៣.១.៣. បន្តបណ្តុះបណ្តាលឧបករណ៍ផ្សព្វផ្សាយ ស្តីពីគ្រួសាររឹងមាំ ជាមួយគ្រួសារគោលដៅនៅតាមសហគមន៍

៣.១.៤. អនុវត្តឧបករណ៍កម្រិតទី៣ នៃការចិញ្ចឹមកូនបែបវិជ្ជមាន

៣.១.៥. ផ្សព្វផ្សាយនិងបណ្តុះបណ្តាលសៀវភៅណែនាំអំពីការកែសម្រួលនិងពង្រីកបន្ថែមនៃយុទ្ធសាស្ត្រ INSPIRE ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ

**លទ្ធផលទី៣.២៖** ដំណើរការយន្តការកិច្ចការពារកុមារតាមសហគមន៍ (CBCPMs)

**សកម្មភាពសំខាន់ៗរួមមាន៖**

៣.៣.១. បង្កើតក្របខ័ណ្ឌការងារជាក់លាក់សម្រាប់យន្តការកិច្ចការពារកុមារតាមសហគមន៍ (CBCPMs) សម្រាប់ទប់ស្កាត់ និងការពារឱ្យបានមុនបញ្ហាកិច្ចការពារកុមារកើតឡើង

៣.២.២. ផ្តល់ការគាំទ្រដល់ គ.ក.ន.ក ដោយផ្អែកលើសៀវភៅណែនាំស្តីពីការការពារកុមារសម្រាប់ឃុំ សង្កាត់ ក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពជាមួយ CBCPMs ជាពិសេសនៅថ្នាក់ភូមិ ក្រុមកុមារ និងក្រុមឪពុកម្តាយ ដើម្បីលើកកម្ពស់ការយល់ដឹងនៅតាមសហគមន៍

## កម្មវិធីទី៤៖ ការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ

**គោលបំណងកម្មវិធីទី៤៖ ដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ ( CPIMS )**

**លទ្ធផលរំពឹងទុកកម្មវិធីទី៤៖ ព័ត៌មាន និងទិន្នន័យស្តីពីកិច្ចការពារកុមារ ត្រូវបានរួមបញ្ចូលឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា និងងាយស្រួលប្រើប្រាស់សម្រាប់អ្នកពាក់ព័ន្ធទាំងអស់**

**លទ្ធផលទី៤.១៖** បច្ចុប្បន្នភាពផ្ទាំងទិន្នន័យ និងប្រព័ន្ធប្រតិបត្តិការដែលនឹងត្រូវបញ្ចូលទៅក្នុង CPIMS

**សកម្មភាពសំខាន់ៗរួមមាន៖**

៤.១.១. ធ្វើបច្ចុប្បន្នភាពទិន្នន័យ CPIMS ប្រចាំឆ្នាំ និងពង្រឹងគុណភាពនិងការភ្ជាប់ទំនាក់ទំនងជាមួយប្រព័ន្ធផ្សេងទៀត រួមទាំងប្រព័ន្ធបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ និងបណ្តាញទូរស័ព្ទជំនួយកុមារ (ទូទាំងក្រសួង និងដៃគូអភិវឌ្ឍន៍)

៤.១.២. ពង្រីកវិសាលភាព នៃកិច្ចព្រមព្រៀងទិន្នន័យរវាងទីភ្នាក់ងារផ្សេងៗជាមួយនឹងប្រត្តិបត្តិការ និងផ្ទាំងទិន្នន័យ (Dashboard) CPIMS

៤.១.៣. បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងសេវាសង្គម

៤.១.៤. បង្កើតអង្គភាព ឬក្រុមការងារបច្ចេកទេស ដើម្បីគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) ដើម្បីដឹកនាំការសម្របសម្រួលគ្រប់គ្រងប្រព័ន្ធព័ត៌មានកិច្ចការពារកុមារ (CPIMS) នៅក្នុង ក្រសួង ស.អ.យ

**លទ្ធផលទី៤.២៖** ការពង្រឹងការគ្រប់គ្រង និងការផ្សារភ្ជាប់ប្រព័ន្ធគ្រប់គ្រងករណី

**សកម្មភាពសំខាន់ៗរួមមាន៖**

៤.២.១. ពង្រឹងសមត្ថភាពក្នុងការប្រើប្រាស់ប្រព័ន្ធ Primero នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ទាំងអស់

៤.២.២. រក្សាធ្វើបច្ចុប្បន្នភាព និងគ្រប់គ្រងប្រព័ន្ធ Primero ជាប្រព័ន្ធតែមួយដែលមានសុវត្ថិភាពសម្រាប់ប្រព័ន្ធគ្រប់គ្រងករណី

៤.២.៣. ពង្រឹងអន្តរប្រតិបត្តិការរវាងប្រព័ន្ធ Primero និងប្រព័ន្ធ OSCaR និងប្រព័ន្ធផ្សេងៗទៀត ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងព័ត៌មាននិងការគ្រប់គ្រងករណី

## កម្មវិធីទី៥៖ ការបង្កើតយន្តការសម្របសម្រួល

**គោលបំណងកម្មវិធីទី៥៖ បង្កើតយន្តការសម្របសម្រួលវិស័យកិច្ចការពារកុមារ**

**លទ្ធផលរំពឹងទុកកម្មវិធីទី៥៖ រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល មានការសម្របសម្រួល និងសហប្រតិបត្តិការគ្នាបានល្អ ព្រមទាំងផ្តល់ការគាំទ្រគ្នាប្រកបដោយប្រសិទ្ធភាព ដើម្បីទប់ស្កាត់ និងការពារកុមារទៅតាមតម្រូវការរបស់ពួកគេ**

**លទ្ធផលទី៥.១៖** ការបង្កើតយន្តការសម្របសម្រួលបច្ចេកទេសថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារសម្រាប់ការអនុវត្តផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមាររវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ

**សកម្មភាពសំខាន់ៗរួមមាន៖**

៥.១.១. បង្កើតយន្តការសម្របសម្រួលបច្ចេកទេសថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារ (អគ្គនាយកនៃក្រសួងមហាផ្ទៃ ក្រសួង ស.អ.យ ម្ចាស់ជំនួយនានា ទីភ្នាក់ងារសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ ជាមួយអនុក្រុមការងារបើជាការចាំបាច់ដើម្បីផ្តោតលើកុមារអនុវត្តផែនការរួមរបស់ក្រសួងទាំងពីរ

៥.១.២. បង្កើតផែនទីបង្ហាញជាក់លាក់នៃការបង្កើតផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ រវាងក្រសួង ស.អ.យ និងក្រសួងមហាផ្ទៃ ដោយការសម្របសម្រួលយន្តការកម្រិតថ្នាក់ដឹកនាំបច្ចេកទេសនៅថ្នាក់ជាតិ

៥.១.៣. ធ្វើការប្រជុំជាប្រចាំនៅថ្នាក់ជាតិ ដើម្បីពិភាក្សាអំពីវឌ្ឍនភាពរួម (យ៉ាងតិចមួយដងក្នុងមួយឆ្នាំ) បញ្ហាប្រឈម និងមេរៀនពិសោធន៍ដែលទាក់ទងនឹងបញ្ហាកិច្ចការពារកុមារ

**លទ្ធផលទី៥.២៖** ការបង្កើត និងពង្រឹងយន្តការសម្របសម្រួលក្រុមការងារកិច្ចការពារកុមារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

**សកម្មភាពសំខាន់ៗរួមមាន៖**

៥.២.១. បង្កើត និងពង្រឹងយន្តការសម្របសម្រួលក្រុមការងារកិច្ចការពារកុមារនៅថ្នាក់រាជធានី ខេត្ត

៥.២.២. បង្កើត និងពង្រឹងយន្តការសម្របសម្រួលក្រុមការងារកិច្ចការពារកុមារនៅថ្នាក់ ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

៥.២.៣. បង្កើតសៀវភៅមគ្គុទេសន៍ នៃសេវាពាក់ព័ន្ធនឹងកិច្ចការពារកុមារនៅកម្រិតសហគមន៍ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលរួមបញ្ចូលទាំងការអន្តរាគមន៍ និងធនធានដែលមានស្រាប់ រួមទាំងធ្វើបច្ចុប្បន្នភាពទៀងទាត់

៥.២.៤. ធ្វើការប្រជុំជាទៀងទាត់នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (យ៉ាងតិចពីរដង ក្នុងមួយឆ្នាំ) ដើម្បីធ្វើបច្ចុប្បន្នអំពីវឌ្ឍនភាពអំពីបញ្ហាប្រឈមដំណោះស្រាយដោយមានការគាំទ្រផ្នែកបច្ចេកទេសពីក្រសួងសាមី។

## ៣.៤. ក្របខ័ណ្ឌផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦

| លទ្ធផល និងសកម្មភាព | ស្ថាប័ន ទទួលខុសត្រូវ | ពេលវេលា |
|---|---|---|
| **កម្មវិធីទី១៖ ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការពង្រឹងប្រព័ន្ធប្រតិបត្តិ**<br>**គោលបំណងកម្មវិធីទី១៖** ពង្រឹងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងប្រតិបត្តិការសម្រាប់កិច្ចការពារកុមារពីការរំលោភបំពានគ្រប់ប្រភេទ ជាពិសេសនៅពេលមានករណីកិច្ចការពារកុមារត្រូវបានរាយការណ៍ (កុមារទាំងអស់ រួមទាំងជនរងគ្រោះសាក្សី និងជនល្មើស)<br>**លទ្ធផលរំពឹងទុកកម្មវិធីទី១៖** មានប្រព័ន្ធកិច្ចការពារកុមារដោយមានកញ្ចប់ថវិកា ធនធានមនុស្ស និងមធ្យោបាយគ្រប់គ្រាន់ ឧទាហរណ៍ សមត្ថភាពក្នុងការស៊ើបអង្កេត និងវាយតម្លៃ នៅពេលកុមារត្រូវបានចាត់ទុកថា ជាជនរងគ្រោះដោយអំពើហិង្សា ឬមានទំនាស់នឹងច្បាប់ និងជម្រើសថៃទាំសមរម្យ ស្របតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ | | |
| **លទ្ធផលទី១.១៖ ការផ្តល់អាជ្ញាប័ណ្ណ និងការទទួលស្គាល់ជាផ្លូវការនូវកម្លាំងសេវាសង្គម** | | |
| សកម្មភាព១.១.១. បង្កើតគោលការណ៍ណែនាំដើម្បីផ្តល់អាជ្ញាប័ណ្ណ និងការទទួលស្គាល់ដល់កម្លាំងសេវាសង្គមកិច្ច | MoSVY | 2022 |
| សកម្មភាព១.១.២. រៀបចំប្រកាសសម្រាប់គណៈកម្មាធិការវាយតម្លៃ ដើម្បីផ្តល់អាជ្ញាប័ណ្ណ | MoSVY | 2023 |
| សកម្មភាព១.១.៣. ផ្សព្វផ្សាយព័ត៌មានអំពីគោលបំណង និងសារៈសំខាន់នៃការផ្តល់អាជ្ញាប័ណ្ណដល់កម្លាំងសេវាសង្គម | MoSVY | 2023 |
| **លទ្ធផលទី១.២៖ ការពង្រឹងប្រព័ន្ធគ្រប់គ្រងករណី និងប្រព័ន្ធត្រួតពិនិត្យសម្រាប់អន្តរាគមន៍កិច្ចការពារកុមារនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ** | | |
| សកម្មភាព១.២.១. ពង្រឹងការគ្រប់គ្រងករណីតាមកម្មវិធីសិក្សា សម្រាប់កម្លាំងសេវាសង្គមកិច្ចកម្រិត២ តាមរយៈការពង្រឹងសមត្ថភាពដល់ថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ | MoSVY/MoI | 2022-2026 |
| សកម្មភាព១.២.២. ពង្រីកប្រព័ន្ធ Primero ដែលជាឧបករណ៍គ្រប់គ្រងករណីទៅគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ទាំងអស់ ដោយផ្សារភ្ជាប់ទៅនឹងប្រព័ន្ធគ្រប់គ្រងករណីអូស្កា(OSCaR) និងឧបករណ៍គ្រប់គ្រងករណីផ្សេងទៀតដែលដៃគូអភិវឌ្ឍន៍កំពុងប្រើប្រាស់ | MoSVY/MoI | 2022-2026 |
| សកម្មភាព១.២.៣. បង្កើត និងដំណើរការប្រព័ន្ធត្រួតពិនិត្យសម្រាប់ការគ្រប់គ្រងករណីលើករណីកិច្ចការពារកុមារដល់មន្ត្រីរាជការ និងដៃគូអភិវឌ្ឍន៍ ដោយមានការសម្របសម្រួលជាមួយអ្នកជំនាញពីស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដោយរួមទាំងមន្ទីរសង្គមកិច្ចជាអ្នកផ្តល់ការត្រួតពិនិត្យផ្នែកបច្ចេកទេស និងការគាំទ្រ | MoSVY/MoI | 2022-2026 |
| **លទ្ធផលទី១.៣៖ ការរៀបចំបទដ្ឋាននីតិវិធីប្រតិបត្តិស្តីពីកិច្ចការពារកុមារ (SOP) រួមទាំងក្របខ័ណ្ឌធានាគុណភាពស្តង់ដារអប្បបរមា និងនីតិវិធីត្រួតពិនិត្យនិងតាមដាន** | | |
| ១.៣.១. បង្កើតបទដ្ឋាននីតិវិធីប្រតិបត្តិស្តីពីកិច្ចការពារកុមារ (SOP) ពាក់ព័ន្ធនឹងកិច្ចការពារកុមារ | MoI/MoSVY | 2023 |
| ១.៣.២. កសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធសំខាន់ៗ ដែលបានកំណត់ដោយបទដ្ឋាននីតិវិធីប្រតិបត្តិស្តីពីកិច្ចការពារកុមារ (SOP) | MoI/MoSVY | 2022-2026 |
| សកម្មភាព១.៣.៣. បង្កើតតារាងលំហូរការងារថ្នាក់ក្រោមជាតិច្បាស់លាស់ និងការកំណត់អត្តសញ្ញាណ រួមទាំងរចនាសម្ព័ន្ធបញ្ជូនបន្ត | MoI/MoSVY | 2024 |
| ១.៣.៤. ធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គម ដោយបន្សីគ្នានឹងសូចនាករដែលមានស្រាប់ទាក់ទងកិច្ចការពារកុមារ សម្រាប់ឃុំ សង្កាត់ | MoI/MoSVY | 2022-2026 |
| **លទ្ធផលទី១.៤៖ ការកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការរៀបចំផែនការកិច្ចការពារកុមារនិងថវិកា** | | |
| សកម្មភាព១.៤.១. កៀរគរថវិកាកិច្ចការពារកុមារ និងសមត្ថភាពរៀបចំផែនការសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដោយផ្អែកលើគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ និងសៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់ ឃុំ សង្កាត់ | MoI/MoSVY | 2022-2026 |

| | | |
|---|---|---|
| សកម្មភាព១.៤.២. ពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ឃុំ សង្កាត់ លើការគ្រប់គ្រងករណីតាមកម្មវិធីសិក្សាសម្រាប់កម្លាំងសេវា សង្គមកិច្ចកម្រិត៣ | MoSVY/MoI | 2022-2026 |
| **លទ្ធផលទី១.៥៖ ការរៀបចំផែនការប្រតិបត្តិកិច្ចការពារកុមារនៅថ្នាក់ក្រោមជាតិ** | | |
| សកម្មភាព១.៥.១. ជំរុញការអនុវត្តផែនការប្រតិបត្តិថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ស្តីពីកិច្ចការពារកុមា | MoSVY | 2022 |
| សកម្មភាព១.៥.២. បង្កើតទទ្បីករសម្រាប់វិនិយោគលើកម្លាំងសេវាសង្គម និងការផ្តល់ថវិកាដល់ការអនុវត្តផែនការកិច្ចការពារកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | MoSVY | 2023 |
| **លទ្ធផលទី១.៦៖ ការបង្កើតការកំណត់អត្តសញ្ញាណ ការប៉ាន់ប្រមាណ ការបញ្ជូន និងយន្តការរាយការណ៍អំពីករណីកិច្ចការពារកុមារកម្រិតធ្ងន់នៅក្នុងសហគមន៍** | | |
| សកម្មភាព១.៦.១. ធ្វើបច្ចុប្បន្នភាពផែនទីសេវាសង្គម និងពង្រឹងយន្តការរាយការណ៍ដែលមានស្រាប់នៅថ្នាក់ឃុំ សង្កាត់ | MoI/ MoSVY | 2022-2026 |
| សកម្មភាព១.៦.២. ផ្តល់នូវការកសាងសមត្ថភាពដល់ គ.ក.ស.ក, គ.ក.ន.ក អ្នកស្ម័គ្រចិត្តសង្គមកិច្ចសហគមន៍ យន្តការកិច្ចការពារកុមារក្នុងសហគមន៍ អំពីរបៀបរាយការណ៍ កំណត់អត្តសញ្ញាណ និងបញ្ជូនករណីកិច្ចការពារកុមារ ផ្អែកតាមសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ (SOP) | MoI/ MoSVY | 2022-2026 |
| សកម្មភាព១.៦.៣. បង្កើតបណ្តាញរាយការណ៍ពិសេសតាមប្រព័ន្ធអ៊ិនធឺណិតនៅក្នុងក្រសួង ស.អ.យ និងពង្រឹងបណ្តាញទូរសព្ទទាន់ហេតុការណ៍ និងបណ្តាញទូរស័ព្ទ ជំនួយកុមាររបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមក | MoI/ MoSVY | 2023 |
| **លទ្ធផលទី១.៧៖ ការបង្កើត និងអនុវត្តគោលនយោបាយ ឬគោលការណ៍ណែនាំស្តីពីការគាំទ្រដល់គ្រួសារ** | | |
| សកម្មភាព១.៧.១. រៀបចំផែនទីថ្នាក់ជាតិ ស្តីពីសេវាគាំទ្រគ្រួសារដែលមានស្រាប់ | MoSVY | 2022 |
| សកម្មភាព១.៧.២. បង្កើត និងអនុវត្តគោលនយោបាយ ឬគោលការណ៍ណែនាំ ស្តីពីការគាំទ្រដល់គ្រួសារជាលក្ខណៈស្តង់ដាជាតិ ដោយមានផែនការត្រួតពិនិត្យ និងវាយតម្លៃច្បាស់លាស់ក្នុងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ | MoSVY | 2023 |
| សកម្មភាព១.៧.៣.ផ្សារភ្ជាប់ការអនុវត្ត និងធនធានពីកិច្ចការគាំពារសង្គមជាមួយនឹងគោលនយោបាយ ឬគោលការណ៍ណែនាំស្តីពីការគាំទ្រដល់គ្រួសារ | MoSVY | 2022-2026 |
| **លទ្ធផលទី១.៨៖ ការបង្កើតក្រមសីលធម៌សម្រាប់កម្លាំងសេវាសង្គម (SSWF) និងសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គម និងបណ្តុះបណ្តាល** | | |
| សកម្មភាព១.៨.១. រៀបចំអនុក្រឹត្យស្តីពីក្រមសីលធម៌សម្រាប់កម្លាំងសេវាសង្គម និងបណ្តុះបណ្តាល | MoSVY | 2022 |
| សកម្មភាព១.៨.២. រៀបចំក្រមសីលធម៌សម្រាប់កិច្ចការពារកុមារ | MoSVY | 2023 |
| សកម្មភាព១.៨.៣. រៀបចំឯកសារបណ្តុះបណ្តាលស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងការងារសង្គម និងធ្វើការបណ្តុះបណ្តាល | MoSVY/MoI | 2022-2026 |
| **លទ្ធផលទី១.៩៖ ការពង្រឹងសេវាថែទាំ និងសមាហរណកម្មទៅក្នុងគ្រួសារនិងសហគមន៍** | | |
| សកម្មភាព១.៩.១. បន្តរៀបចំសៀវភៅណែនាំស្តីពីនីតិវិធីអនុវត្តមុខងារសម្រាប់មន្ត្រីទទួលបន្ទុកជាបុគ្គលិកសង្គមកិច្ច អ្នកអាជីពរង រឺអត់រងនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ | MoSVY/MoI | 2022-2023 |
| សកម្មភាព១.៩.២. ពង្រឹងការតាមដានត្រួតពិនិត្យ និងគាំទ្របច្ចេកទេសចំពោះករណីកុមាររងគ្រោះ និងងាយរងគ្រោះ | MoSVY/MoI | 2022-2026 |
| សកម្មភាព១.៩.៣. ពង្រឹងការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នីមួយៗ ពាក់ព័ន្ធនឹងកិច្ចការពារកុមារ | MoSVY/MoI | 2022-2026 |
| សកម្មភាព១.៩.៤. បង្កើនការបញ្ជូនករណីកិច្ចការពារកុមារពីឃុំ សង្កាត់ ទៅក្រុង ស្រុក ខណ្ឌ និងផ្តល់សេវាដល់កុមារនិងគ្រួសារដែលរងគ្រោះនិងងាយរងគ្រោះ | MoI/ MoSVY | 2022-2026 |

| | | |
|---|---|---|
| សកម្មភាព១.៩.៥. បង្កើនចំនួនបុគ្គលិកសង្គម នៅថ្នាក់ក្រុង ស្រុក ខណ្ឌ តាមរយៈ ការជ្រើសរើសថ្មី ឬការតែងតាំងមន្ត្រីរាជការដែលមានស្រាប់ | MoSVY/MoI | 2022-2026 |
| **លទ្ធផលទី១.១០៖ ការបង្កើត និងអនុវត្តសាកល្បងបទដ្ឋានអប្បបរមា នៃសេវាកិច្ចការពារកុមារនៅតាមក្រុង ស្រុក ខណ្ឌនីមួយៗ (បទដ្ឋាននីតិវិធីប្រតិបត្តិស្តីពីកិច្ចការពារកុមារ)** | | |
| សកម្មភាព១.១០.១. បង្កើតបទដ្ឋានអប្បរមានៃសេវាកិច្ចការពារកុមារសម្រាប់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលផ្តោតលើបទដ្ឋាននីតិវិធីប្រតិបត្តិស្តីពីកិច្ចការពារកុមារ | MoSVY/MoI | 2022 |
| សកម្មភាព១.១០.២. អនុវត្តសាកល្បងបទដ្ឋានអប្បបរមានៃសេវាកិច្ចការពារកុមារ សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ មួយចំនួន | MoSVY/MoI | 2023-2024 |
| សកម្មភាព១.១០.៣. ធ្វើការវាយតម្លៃទៅលើលទ្ធផលនៃការអនុវត្តបទដ្ឋានអប្បបរមា នៃសេវាកិច្ចការពារកុមារ និងពង្រីកឱ្យបានគ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស | MoSVY/MoI | 2024 |
| **លទ្ធផលទី១.១១៖ ការបង្កើតរបាយការណ៍ជាក់លាក់ និងមធ្យោបាយបញ្ជូន** | | |
| សកម្មភាព១.១១.១. វិភាគសេវាកម្មសាធារណៈ និងទីភ្នាក់ងារដែលមានកាតព្វកិច្ច ទទួលបន្ទុកក្នុងការរាយការណ៍ | MoSVY | 2022 |
| ១.១១.២. សម្របសម្រួលជាមួយបណ្តាញប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ និងប្រព័ន្ធជំនួយដល់កុមារដើម្បីបង្កើតជាមធ្យោបាយច្បាស់លាស់ ក្នុងការបញ្ជូនករណីដល់អាជ្ញាធរផ្អែកលើបទដ្ឋាននីតិវិធីប្រតិបត្តិ (SOP) | MoSVY | 2022-2026 |
| **កម្មវិធីទី២៖ ការពង្រឹង និងពង្រីកសេវាគោលដៅក្នុងការបង្ការទប់ស្កាត់ និងសេវាគាំទ្រ**<br>**គោលបំណងកម្មវិធីទី២៖** ផ្តល់សេវាបង្ការទប់ស្កាត់ និងសេវាគាំទ្រ សម្រាប់គ្រួសារគោលដៅដែលមានតម្រូវការ<br>**លទ្ធផលរំពឹងទុកកម្មវិធីទី២៖** កុមារ និងគ្រួសារដែលបានជួបប្រទះ ឬប្រឈមនឹងអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច ការមិនយកចិត្តទុកដាក់ និងប្រព្រឹត្តបទល្មើស ទទួលបានសេវាការពារ និងការថែរក្សាក្នុងគ្រួសារ (ការគាំទ្រគ្រួសារ និងការគាំពារសង្គមផ្សេងទៀត) | | |
| **លទ្ធផលទី២.១៖ ការពង្រឹង និងការពង្រីកការសម្របសម្រួលសេវាបង្ការទប់ស្កាត់តាមសហគមន៍សម្រាប់គ្រួសារ ដែលមានកុមារងាយរងគ្រោះនិងងាយរងគ្រោះ** | | |
| សកម្មភាព២.១.១. កំណត់អត្តសញ្ញាណកុមារដែលរងគ្រោះ និងងាយរងគ្រោះ និងតម្រូវការរបស់ពួកគេទៅតាមអាយុ និងភេទ ដើម្បីងាយស្រួលផ្តល់សេវាគាំទ្រ | MoSVY/MoI | 2022-2026 |
| សកម្មភាព២.១.២. ពង្រឹងការត្រួតពិនិត្យតាមដានការអនុវត្តប្រកាសស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ ព្រមទាំងគោលនយោបាយ និងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ | MoSVY/MoI | 2022-2026 |
| សកម្មភាព២.១.៣. លើកកម្ពស់ការទុកដាក់កុមារជាអចិន្ត្រៃយ៍ រាប់បញ្ចូលទាំងការសុំកូនក្នុងប្រទេស | MoSVY/MoI | 2022-2026 |
| សកម្មភាព២.១.៤. ផ្តល់សេវាដើម្បីបង្ការ និងទប់ស្កាត់កុមារដែលងាយរងគ្រោះក្នុងការបែកចេញពីគ្រួសារ | MoSVY/MoI | 2022-2026 |
| សកម្មភាព២.១.៥ បង្កើត និងអនុវត្តយន្តការត្រួតពិនិត្យសម្រាប់អ្នកថែទាំដែលជាឪពុកម្តាយធម៌ សាច់ញាតិ និងអ្នកផ្តល់សេវាសុំកូន ផ្អែកតាមគោលនយោបាយ និងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ | MoSVY/MoI | 2022-2026 |
| សកម្មភាព២.១.៦. ផ្តល់នូវបណ្តាញសុវត្ថិភាព (ការគាំទ្រជាសាច់ប្រាក់និងសេវាគាំពារសង្គមផ្សេងទៀតតាមរយៈរាជរដ្ឋាភិបាលនិងការកៀរគរធនធាននានា មកពីដៃគូអភិវឌ្ឍន៍វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល) | MoSVY/MoI | 2022-2026 |
| សកម្មភាព២.១.៧. ផ្តល់ការពង្រឹងសេដ្ឋកិច្ចដល់គ្រួសារ ផ្តោតលើគ្រួសារគោលដៅដែលមានកុមារងាយរងគ្រោះ | MoSVY/MoI | 2022-2026 |
| សកម្មភាព២.១.៨. ផ្តល់ការគាំទ្រឪពុកម្តាយធម៌ និងសាច់ញាតិ ផ្សារភ្ជាប់ទៅការគាំទ្រការគាំពារសង្គម | MoSVY/MoI | 2022-2026 |

| | | |
|---|---|---|
| សកម្មភាព២.១.៩. ផ្សារភ្ជាប់ប្រព័ន្ធ Primero និងសេចក្តីព្រាងអនុក្រឹត្យ ដើម្បីគាំទ្រដល់ប្រជាជនដែលងាយរងគ្រោះ ដោយរួមបញ្ចូលទាំងការគាំទ្រដល់គ្រួសារ ដែលមានកុមារងាយរងគ្រោះត្រូវការគាំទ្រ | MoSVY/MoI | 2022-2026 |
| **លទ្ធផលទី២.២៖ ការពង្រឹងការថែរក្សាកុមារក្នុងគ្រួសារ** | | |
| សកម្មភាព២.២.១. បន្តអនុវត្តសៀវភៅណែនាំសម្រាប់ គ.ក.ន.ក ដើម្បីធ្វើឱ្យប្រសើរឡើងនូវការថែទាំកុមារ និងការវិលត្រឡប់របស់ពួកគេប្រកបដោយសុវត្ថិភាព | MoI/ MoSVY | 2022-2026 |
| សកម្មភាព២.២.២. ពិនិត្យឡើងវិញនូវឯកសារបណ្តុះបណ្តាលការថែរក្សាកុមារក្នុងគ្រួសារដែលមានស្រាប់ និងកំពុងអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល សហការជាមួយក្រសួង ស.អ.យ និងដាក់ឱ្យដំណើរការទៅអ្នកថែរក្សាកុមារ | MoSVY | 2022-2026 |
| សកម្មភាព២.២.៣. កំណត់អត្តសញ្ញាណជនរងគ្រោះ និងបញ្ជូនបន្តទៅរកសេវាសង្គមផ្សេងៗដែលចាំបាច់សម្រាប់គ្រួសារ និងកុមារ ដែលអនុលោមទៅតាមកម្មវិធី ផ្ទេរសាច់ប្រាក់ដែលកំពុងអនុវត្តដោយក្រសួង ស.អ.យ | MoSVY | 2022-2026 |
| **លទ្ធផលទី២.៣៖ ការផ្តល់សេវាដល់កុមារដែលទំនាស់នឹងច្បាប់និងកុមារដែលតាមម្តាយនៅក្នុងពន្ធនាគារ** | | |
| សកម្មភាព ២.៣.១. ធ្វើការប៉ាន់ប្រមាណស្ថានភាពកុមារដែលកំពុងរស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ | MoI/ MoSVY | 2022-2026 |
| សកម្មភាព២.៣.២. ផ្តល់ការគាំទ្រផ្នែកគ្រប់គ្រងករណីដល់កុមារដែលបានកំណត់អត្តសញ្ញាណរួមទាំងធ្វើសមាហរណកម្មទៅថែទាំក្នុងគ្រួសារ ឬសហគមន៍វិញ បើអាចធ្វើទៅបាន | MoI/ MoSVY | 2022-2026 |
| **លទ្ធផលទី២.៤៖ ការអភិវឌ្ឍជំនាញ និងកសាងសមត្ថភាពរបស់កម្លាំងសេវាសង្គម (SSWF) ក្នុងការផ្តល់សេវាកិច្ច ការពារកុមារ (កម្រិតទី២ និងទី៣ នៃផែនការយុទ្ធសាស្ត្របណ្តុះបណ្តាលសេវាសង្គម)** | | |
| សកម្មភាព២.៤.១. បង្កើតវគ្គបណ្តុះបណ្តាល និងយុទ្ធសាស្ត្រជំនាញឯកទេស(ផែនការយុទ្ធសាស្ត្របណ្តុះបណ្តាលសេវាសង្គម និងកម្មវិធីសម្រាប់បង្កើនសមត្ថភាពគ្រប់លំដាប់ថ្នាក់) ការបណ្តុះបណ្តាលរួមទាំងការអប់រំក្នុងប្រព័ន្ធជាផ្លូវការ | MoSVY/MoI | 2022-2026 |
| សកម្មភាព២.៤.២. កសាងសមត្ថភាពយោងតាមយុទ្ធសាស្ត្រ និងកម្មវិធីខាងលើមុននិងអំឡុងពេលផ្តល់សេវា | MoSVY/MoI | 2023 |
| សកម្មភាព២.៤.៣. បង្កើតការងារសម្រាប់មន្ត្រីរាជការដែលមានស្រាប់ពីក្រសួង ស.អ.យ និងក្រសួងមហាផ្ទៃ និស្សិតបញ្ចប់ការសិក្សាពីវិទ្យាស្ថានជាតិសង្គមកិច្ច សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យដទៃផ្សេងទៀត ដើម្បីក្លាយជាមន្ត្រីសាធារណៈដោយផ្អែកលើយុទ្ធសាស្ត្រជាតិស្តីពីកម្លាំងសេវាសង្គម | MoSVY/MoI | 2022-2026 |
| សកម្មភាព២.៤.៤. ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីអង្គការសុវត្ថិភាពកុមារ ដល់គ្រប់អ្នកធ្វើការងារពាក់ព័ន្ធនឹងកិច្ចការពារកុមារ | MoSVY | 2022-2026 |
| **លទ្ធផលទី២.៥៖ ការពង្រឹងសេវាថែទាំ និងសមាហរណកម្មកុមារទៅក្នុងគ្រួសារ និងសហគមន៍** | | |
| សកម្មភាព២.៥.១. ជំរុញការអនុវត្តគោលការណ៍ណែនាំស្តីពីការធ្វើសមាហរណកម្មកុមារ ការបង្វែរកន្លែងថែទាំ និងការបិទកន្លែងថែទាំកុមារ | MoSVY | 2022-2026 |
| សកម្មភាព២.៥.២. ពិនិត្យឡើងវិញលើគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឱ្យស្របតាមគោលការណ៍ណែនាំសម្រាប់ការថែទាំជំនួសចំពោះកុមាររបស់អង្គការសហប្រជាជាតិ និងស្របតាមបរិបទកម្ពុជានាពេលបច្ចុប្បន្ន | MoSVY | 2022 |
| សកម្មភាព២.៥.៣. រៀបចំផែនការករណីសម្រាប់កុមារទាំងអស់ដែលកំពុងស្នាក់នៅក្នុងមណ្ឌល (គ្រប់ករណីទាំងអស់ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងករណីPrimero) និងផ្តល់សេវាសមាហរណកម្ម | MoSVY/MoI | 2022-2026 |
| សកម្មភាព២.៥.៤. សហការជាមួយមណ្ឌលថែទាំកុមារ ដែលមានបំណងធ្វើការបង្វែរកម្មវិធីការថែទាំកុមារក្នុងមណ្ឌល ទៅជាការថែទាំតាមបែបសហគមន៍ ឬបិទមណ្ឌលថែទាំ | MoSVY/MoI | 2022-2026 |

| | | |
|---|---|---|
| សកម្មភាព២.៥.៥. ពង្រឹង និងពង្រីក ការអនុវត្តកម្មវិធីការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ និងការសុំកូន (ក្នុងប្រទេសនិងក្រៅប្រទេស) រួមទាំងកុមារដែល មានពិការភាព | MoSVY/MoI | 2022-2026 |
| សកម្មភាព២.៥.៦. ពង្រឹងការថែទាំកុមារនៅតាមផ្ទះស្នាក់នៅជាក្រុម | MoSVY/MoI | 2022-2026 |
| សកម្មភាព២.៥.៧. ត្រៀមនិងបន្សាំកុមារអំពីការរស់នៅក្នុងសហគមន៍មុនពេលចាកចេញពីមណ្ឌលថែទាំ | MoSVY/MoI | 2022-2026 |
| សកម្មភាព២.៥.៨. បន្តតាមដាន និងផ្តល់ការគាំទ្រកុមារដែលចាកចេញពីមណ្ឌល ថែទាំ | MoSVY/MoI | 2022-2026 |
| **លទ្ធផលទី២.៦៖ ប្រតិបត្តិការកិច្ចការពារកុមារក្នុងស្ថានភាពគ្រោះអាសន្ន** | | |
| សម្មភាព២.៦.១. អនុវត្តនិងធ្វើបច្ចុប្បន្នភាពផែនការកិច្ចការពារកុមារក្នុងគ្រាអាសន្ន | MoSVY | 2022-2026 |
| សកម្មភាព២.៦.២. ផ្តល់ការកសាងសមត្ថភាពដល់អ្នកផ្តល់សេវា ដែលពាក់ព័ន្ធទៅនឹងការងារកិច្ចការពារកុមារអំពីស្តង់ដារអប្បបរមានៃការងារកិច្ចការពារកុមារ | MoSVY | 2022-2026 |
| **កម្មវិធីទី៣៖ ការពង្រឹង និងពង្រីកសេវាផ្សព្វផ្សាយ**<br>**គោលបំណងកម្មវិធីទី៣៖** លើកកម្ពស់និយាមសង្គមដែលវិជ្ជមាន<br>**លទ្ធផលរំពឹងទុកកម្មវិធីទី៣៖** គ្រួសារ សាលារៀន និងសហគមន៍ នឹងថែរក្សាចិញ្ចឹមបីបាច់កុមារក្នុងបរិយាកាសសុវត្ថិភាព ហើយការចិញ្ចឹមកូនបែបវិជ្ជមាននឹងត្រូវបានផ្តល់ជូនដល់ឪពុកម្តាយនិងអាណាព្យាបាល និងអ្នករស់នៅក្នុងសហគមន៍ ទាំងអស់ | | |
| **លទ្ធផលទី៣.១៖ ការបង្កើនការផ្សព្វផ្សាយយុទ្ធនាការគ្រួសាររឹងមាំ នៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT) និងយុទ្ធនាការផ្លាស់ប្តូរអាកប្បកិរិយាផ្សេងៗ** | | |
| សកម្មភាព៣.១.១. បន្តអនុវត្តន៍យុទ្ធនាការគ្រួសាររឹងមាំ នៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT) | MoSVY | 2022-2026 |
| សកម្មភាព៣.១.២. បញ្ចូលបញ្ហានៃអ្នកស្រឡាញ់ភេទដូចគ្នា និងការរើសអើងយេនឌ័រទៅក្នុងយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង (Cambodia PROTECT) | MoSVY | 2023 |
| សកម្មភាព៣.១.៣. បន្តបណ្តុះបណ្តាលឧបករណ៍ផ្សព្វផ្សាយស្តីពីគ្រួសាររឹងមាំជាមួយគ្រួសារគោលដៅនៅតាមសហគមន៍ | MoSVY | 2022-2026 |
| សកម្មភាព៣.១.៤. អនុវត្តឧបករណ៍កម្រិតទី៣ នៃការចិញ្ចឹមកូនបែបវិជ្ជមាន | MoSVY | 2022-2026 |
| សកម្មភាព៣.១.៥. ផ្សព្វផ្សាយនិងបណ្តុះបណ្តាលសៀវភៅណែនាំអំពីការកែសម្រួល និងពង្រីកបន្ថែមនៃយុទ្ធសាស្ត្រ INSPIRE ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ | MoSVY | 2022-2026 |
| **លទ្ធផលទី៣.២៖ ដំណើរការយន្តការកិច្ចការពារកុមារតាមសហគមន៍(CBCPMs)** | | |
| សកម្មភាព៣.២.១. បង្កើតក្របខណ្ឌការងារជាក់លាក់សម្រាប់យន្តការកិច្ចការពារកុមារតាមសហគមន៍ (CBCPMs) សម្រាប់ទប់ស្កាត់ និងការពារឱ្យបានមុនបញ្ហាកិច្ចការពារកុមារកើតឡើង | MoI | 2023 |
| សកម្មភាព៣.២.២. ផ្តល់ការគាំទ្រដល់ គ.ក.ន.ក ដោយផ្អែកលើសៀវភៅណែនាំស្តីពីការការពារកុមារសម្រាប់ឃុំ សង្កាត់ របស់ក្រសួងមហាផ្ទៃ ក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពជាមួយ CBCPMs ជាពិសេសនៅថ្នាក់ភូមិ ក្រុមកុមារ និងក្រុមឪពុកម្តាយ ដើម្បីលើកកម្ពស់ការយល់ដឹងនៅតាមសហគមន៍ | MoI | 2022-2026 |
| **កម្មវិធីទី៤៖ ការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ**<br>**គោលបំណងកម្មវិធីទី៤៖** ដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ (CPIMS)<br>**លទ្ធផលរំពឹងទុកកម្មវិធីទី៤៖** ព័ត៌មាន និងទិន្នន័យស្តីពីកិច្ចការពារកុមារត្រូវបានរួមបញ្ចូលឱ្យប្រទាក់ក្រឡាគ្នានិងងាយស្រួលប្រើប្រាស់សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ | | |
| **លទ្ធផលទី៤.១៖ បច្ចុប្បន្នភាពផ្ទាំងទិន្នន័យ និងប្រព័ន្ធប្រតិបត្តិការដែលនឹងត្រូវបញ្ចូលទៅក្នុង CPIMS** | | |
| សកម្មភាព៤.១.១. ធ្វើបច្ចុប្បន្នភាពទិន្នន័យ CPIMS ប្រចាំឆ្នាំ និងពង្រឹងគុណភាព និងការភ្ជាប់ជាមួយប្រព័ន្ធផ្សេងទៀត រួមទាំងប្រព័ន្ធបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ និងបណ្តាញទូរសព្ទជំនួយកុមារ (ទូទាំងក្រសួង និងដៃគូអភិវឌ្ឍន៍) | MoSVY with other 11 Ministries and 2 NGO networks | 2023 |
| សកម្មភាព៤.១.២. ពង្រីកវិសាលភាពនៃកិច្ចព្រមព្រៀង ការតភ្ជាប់ប្រព័ន្ធទិន្នន័យ រវាងទីភ្នាក់ងារផ្សេងៗជាមួយនឹងប្រត្តិបត្តិការ និងផ្ទាំងទិន្នន័យ (Dashboard) CPIMS | | 2023 |

| | | |
|---|---|---|
| សកម្មភាព៤.១.៣. បង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងទិន្នន័យកម្លាំងសេវាសង្គម | | 2023 |
| សកម្មភាព៤.១.៤. បង្កើតអង្គភាព ឬក្រុមការងារបច្ចេកទេស ដើម្បីគ្រប់គ្រងបច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មាន (ICT) ដើម្បីដឹកនាំការសម្របសម្រួលការគ្រប់គ្រងប្រព័ន្ធព័ត៌មានកិច្ចការពារកុមារ (CPIMS)នៅក្នុងក្រសួង ស.អ.យ | | 2022-2026 |
| **លទ្ធផលទី៤.២៖ ការពង្រឹងការគ្រប់គ្រង និងការផ្សារភ្ជាប់ប្រព័ន្ធគ្រប់គ្រងករណី** | | |
| សកម្មភាព៤.២.១. ពង្រឹងសមត្ថភាពក្នុងការប្រើប្រាស់ប្រព័ន្ធ Primero នៅថ្នាក់រាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ ទាំងអស់ | MoSVY/MoI | 2022-2026 |
| សកម្មភាព៤.២.២. រក្សាធ្វើបច្ចុប្បន្នភាព និងគ្រប់គ្រងប្រព័ន្ធ Primero ជាប្រព័ន្ធតែមួយដែលមាន សុវត្ថិភាពសម្រាប់ប្រព័ន្ធគ្រប់គ្រងករណី | MoSVY/MoI | 2022-2026 |
| សកម្មភាព៤.២.៣. ពង្រឹងអន្តរប្រតិបត្តិការរវាងប្រព័ន្ធ Primero និងប្រព័ន្ធ OSCaR និងប្រព័ន្ធ ផ្សេងៗទៀត ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រប់ព័ត៌មាន និងការគ្រប់គ្រងករណី | MoSVY/MoI | 2022-2026 |
| **ផ្នែកទី៥៖ ការបង្កើតយន្តការសម្របសម្រួល**<br>**គោលបំណងកម្មវិធីទី៥៖** បង្កើតយន្តការសម្របសម្រួលវិស័យកិច្ចការពារកុមាររវាងក្រសួង ស.អ.យ និងក្រសួងមហាផ្ទៃ<br>**លទ្ធផលរំពឹងទុកកម្មវិធីទី៥៖** រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ធ្វើការសម្របសម្រួលសហប្រតិបត្តិការ ព្រមទាំងផ្តល់ការគាំទ្រគ្នាប្រកបដោយប្រសិទ្ធភាព ក្នុងការទប់ស្កាត់ និងការការពារកុមារទៅតាមតម្រូវការរបស់ពួកគេ | | |
| **លទ្ធផលទី៥.១៖ ការបង្កើតយន្តការសម្របសម្រួលបច្ចេកទេសថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារសម្រាប់ការអនុវត្តផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមាររវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ** | | |
| សកម្មភាព៥.១.១. បង្កើតយន្តការសម្របសម្រួលបច្ចេកទេសថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារ (អគ្គនាយកនៃក្រសួងមហាផ្ទៃ ក្រសួង ស.អ.យ ម្ចាស់ជំនួយនានា អង្គការសហប្រជាជាតិ និង ដៃគូអភិវឌ្ឍន៍ )ជាមួយអនុក្រុម រឺអនុក្រុម បើជាការចាំបាច់ ដើម្បីផ្តោតលើការអនុវត្តផែនការរួម របស់ក្រសួងទាំងអស់ | MoI/ MoSVY | 2022 |
| សកម្មភាព៥.១.២. បង្កើតផែនទី រឺផែនការ បង្ហាញជាក់លាក់នៃការបង្កើតផែនអនុវត្តយុទ្ធសាស្ត្រ វិស័យកិច្ចការពារកុមាររវាងក្រសួង ស.អ.យ និងក្រសួងមហាផ្ទៃ ដោយការសម្របសម្រួលយន្តការ កម្រិតថ្នាក់ដឹកនាំបច្ចេកទេសនៅថ្នាក់ជាតិ | MoI/ MoSVY | 2022-2026 |
| សកម្មភាព៥.១.៣. ធ្វើការប្រជុំជាប្រចាំនៅថ្នាក់ជាតិ (យ៉ាងតិចពីរដងក្នុងមួយឆ្នាំ) ដើម្បីពិភាក្សា អំពីវឌ្ឍនភាពរួម បញ្ហាប្រឈម និងមេរៀនពិសោធន៍ដែលទាក់ទងនឹងបញ្ហាកិច្ចការពារកុមារ | MoI/ MoSVY | 2022-2026 |
| **លទ្ធផលទី៥.២៖ ការបង្កើត និងពង្រឹងយន្តការសម្របសម្រួលក្រុមការងារកិច្ចការពារកុមារនៅថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់** | | |
| សកម្មភាព៥.២.១. បង្កើត និងពង្រឹងយន្តការសម្របសម្រួលក្រុមការងារកិច្ចការពារកុមារ នៅ ថ្នាក់រាជធានី ខេត្ត | MoI/ MoSVY | 2022-2026 |
| សកម្មភាព៥.២.២. បង្កើត និងពង្រឹងយន្តការសម្របសម្រួលក្រុមការងារកិច្ចការពារកុមារ នៅ ថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ | MoI/ MoSVY | 2022-2026 |
| សកម្មភាព៥.២.៣. បង្កើតសៀវភៅមគ្គុទេសន៍ នៃសេវាពាក់ព័ន្ធនឹងកិច្ចការពារកុមារ មាននៅ កម្រិតសហគមន៍ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងកម្រិតសហគមន៍ ដែលរួមបញ្ចូលទាំងអន្តរាគមន៍និងធនធានដែលមានស្រាប់ និងធ្វើបច្ចុប្បន្នភាពទៀងទាត់ (រាជរដ្ឋាភិបាល និងអង្គការដៃគូ) | MoI/ MoSVY | 2023 |
| សកម្មភាព៥.២.៤. ធ្វើការប្រជុំជាទៀងទាត់នៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើបច្ចុប្បន្នភាព (យ៉ាងតិចពីរដងក្នុងមួយឆ្នាំ) អំពីវឌ្ឍនភាព ពិភាក្សាអំពីបញ្ហាប្រឈម និង ដំណោះស្រាយដោយមានការគាំទ្រផ្នែកបច្ចេកទេស ពីក្រសួងសាមី | MoI/ MoSVY | 2022-2026 |

# ជំពូកទី៤

## ការប៉ាន់ស្មានចំណាយ និងយុទ្ធសាស្ត្រហិរញ្ញប្បទានសម្រាប់អនុវត្តផែនការ អនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦

ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦ ត្រូវបានដាក់អនុវត្តដើម្បីការពារកុមារគ្រប់រូបពីគ្រប់ទម្រង់នៃការរំលោភបំពានលើរាងកាយ ការរំលោភបំពានផ្លូវអារម្មណ៍ ការរំលោភបំពានផ្លូវភេទ ការមិនអើពើ និងការកេងប្រវ័ញ្ច ដែលជាផ្នែកមួយរួមចំណែកដល់ផែនការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធការពារកុមារ ឆ្នាំ២០១៩-២០២៩ ផងដែរ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ ទទួលខុសត្រូវក្នុងការសហការដឹកនាំអភិវឌ្ឍន៍អនុវត្តតាមដាន និងវាយតម្លៃផែនការនេះ។ តាមរយៈការបង្កើតយន្តការសម្របសម្រួលថ្នាក់ជាតិកម្រិតអគ្គនាយកដ្ឋានរវាងក្រសួង ស.អ.យ និងក្រសួងមហាផ្ទៃ ក្រុមបច្ចេកទេសរបស់ក្រសួង ទាំងពីរដែលមកពីនាយកដ្ឋានពាក់ព័ន្ធរួមជាមួយម្ចាស់ជំនួយនិងដៃគូអភិវឌ្ឍន៍នៅថ្នាក់ជាតិ នឹងធ្វើការត្រួតពិនិត្យផែនការនេះឱ្យកាន់តែមានប្រសិទ្ធភាព រួមទាំងការផ្តល់ជំនួយបច្ចេកទេសដល់ថ្នាក់ក្រោមជាតិឱ្យអនុវត្តទៅតាមតួនាទី និងភារកិច្ចរបស់ពួកគេ។

នៅថ្នាក់ក្រោមជាតិ៖ ផែនការនេះនឹងបន្តពង្រឹងសេវាបញ្ជូនករណីកិច្ចការពារកុមារពីថ្នាក់ភូមិ ទៅឃុំ សង្កាត់ ទៅដល់ថ្នាក់ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ស្របតាមគោលនយោបាយ និងច្បាប់ពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា។ គ.ក.ន.ក នឹងបំពេញតួនាទីដែលបានកំណត់ផ្នែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលមានតួនាទីក្នុងការការពារទប់ស្កាត់ និងបញ្ជូនករណីកិច្ចការពារកុមារទៅមន្ត្រីសង្គមកិច្ច និងដៃគូអភិវឌ្ឍន៍ដែលមានក្នុងតំបន់របស់ពួកគេ ដើម្បីឆ្លើយតបទៅលើករណីទាំងនោះ។ សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត (គ.ក.ស.ក) នឹងត្រូវបានបង្កើនដើម្បីជួយគាំទ្រដល់កម្លាំងសេវាសង្គមកិច្ចថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្តសេវាប្រកបដោយប្រសិទ្ធភាព។

ដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងអន្តរជាតិសំខាន់ៗ បាននិងកំពុងផ្តល់សេវាសុខុមាលភាពសង្គម និងសេវាកិច្ចការពារកុមារតាមរយៈកម្មវិធីមួយចំនួន រួមទាំងការគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួង ស.អ.យ និងក្រសួងមហាផ្ទៃ ទាក់ទងនឹងការបង្កើតគោលនយោបាយ ឬសេចក្តីណែនាំ និងការអនុវត្តផែនការយុទ្ធសាស្ត្រនានាផងដែរ។ នៅក្នុងនោះមានបណ្តាញអង្គការដៃគូចម្បងៗពីរដែលរួមមានបណ្តាញដៃគូ FCFREACT គឺជាបណ្តាញដែលដឹកនាំដោយអង្គការ Save the Children មានសមាជិកលើសពី ៦០ស្ថាប័ន និងបណ្តាញដៃគូសម្រាប់ការការពារកុមារ (3PC) ដឹកនាំដោយអង្គការ Friend International មានដៃគូបណ្តាញចំនួន ៤០ស្ថាប័ន។ ពួកគេមិនបានផ្តល់មូលនិធិដោយផ្ទាល់ដល់រាជរដ្ឋាភិបាលទេ ប៉ុន្តែពួកគេបានចូលរួមអនុវត្តសកម្មភាពនៃកម្មវិធីរបស់ក្រសួង។

ក្រសួង ស.អ.យ និងក្រសួងមហាផ្ទៃ បាននិងកំពុងដំណើរការកម្មវិធីតាមរយៈថវិកាជាតិ និងទទួលបានការគាំទ្រមូលនិធិពីដៃគូអភិវឌ្ឍន៍ រួមមាន អង្គការយូនីសេហ្វ ទីភ្នាក់ងារជំនួយសហរដ្ឋអាមេរិក និងរដ្ឋាភិបាលជប៉ុន ដែលជាម្ចាស់ជំនួយដ៏សំខាន់។ ក្រសួង ស.អ.យ និងក្រសួងមហាផ្ទៃ នឹងបញ្ចូលសកម្មភាពទៅក្នុងផែនការថវិកាកម្មវិធីប្រចាំឆ្នាំ។ លើសពីនេះ ក្រសួងនឹងបន្តកសាងភស្តុតាងបន្ថែមទៀតនៅក្នុងករណីកិច្ចការពារកុមារ និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសម្រាប់បង្ហាញជូនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបញ្ជាក់ក្នុងការសម្រេចចិត្ត ដើម្បីបង្កើនថវិកាជាតិគាំទ្រផែនការយុទ្ធសាស្ត្រ។ ក្រសួង ស.អ.យ និងក្រសួងមហាផ្ទៃ ក៏នឹងបន្តសហការជាមួយដៃគូអភិវឌ្ឍន៍ និងភ្នាក់ងារឯកជន (ប្រសិនបើមាន) នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាថា មានធនធានគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការនៃបញ្ហាកិច្ចការពារកុមារនៅក្នុងប្រទេសកម្ពុជា ដូចដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រនេះផងដែរ។

## តារាងទី១៖ ថវិកាប៉ាន់ស្មានសម្រាប់ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦

| | ចំណាយប៉ាន់ស្មាន ( ដុល្លារសហរដ្ឋអាមេរិក ) | | | | | សរុប | ភាគរយនៃថវិកាសរុប រយៈពេល ៥ ឆ្នាំ |
|---|---|---|---|---|---|---|---|
| | 2022 | 2023 | 2024 | 2025 | 2026 | | |
| **កម្មវិធីទី១៖** ការរៀបចំលិខិតបទដ្ឋានគតិយុត្តិ និងពង្រឹងប្រព័ន្ធប្រតិបត្តិការ | $2,907,472 | $2,557,494 | $2,383,217 | $2,339,727 | $2,339,727 | $12,527,637 | 41.7% |
| **កម្មវិធីទី២៖** ការពង្រីកសេវាគោលដៅក្នុងការបង្ការទប់ស្កាត់ | $2,572,831 | $2,576,356 | $2,546,571 | $2,546,571 | $2,546,571 | $12,788,900 | 42.5% |
| **កម្មវិធីទី៣៖** ការពង្រឹង និងពង្រីកសេវាផ្សព្វផ្សាយ | $607,950 | $625,200 | $607,950 | $607,950 | $607,950 | $3,057,000 | 10.2% |
| **កម្មវិធីទី៤៖** ការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ | $60,390 | $75,640 | $60,390 | $60,390 | $60,390 | $317,200 | 1.1% |
| **កម្មវិធីទី៥៖** ការបង្កើតយន្តការសម្របសម្រួល | $270,810 | $287,060 | $269,810 | $269,810 | $269,810 | $1,367,300 | 4.5% |
| សរុប | $6,419,453 | $6,121,750 | $5,867,938 | $5,824,448 | $5,824,448 | $30,058,037 | 100.0% |

## រូបភាព ២៖ តម្រូវការថវិកាសម្រាប់ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦



**តារាងទី២៖ ថវិកាប៉ាន់ស្មានប្រចាំឆ្នាំតាមកម្មវិធី និងលទ្ធផលរបស់ផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦**

| លទ្ធផល និងសកម្មភាព | ចំណាយប៉ាន់ស្មាន (ដុល្លារ) | | | | | សរុប |
|---|---|---|---|---|---|---|
| | 2022 | 2023 | 2024 | 2025 | 2026 | (ដុល្លារ) |
| **កម្មវិធីទី១៖ ការរៀបចំលិខិតបទដ្ឋានគតិយុត្តិ និងការពង្រឹងប្រព័ន្ធប្រតិបត្តិ** | $2,907,472 | $2,557,494 | $2,383,217 | $2,339,727 | $2,339,727 | $12,527,637 |
| លទ្ធផលទី១.១. ការផ្តល់អាជ្ញាប័ណ្ណ និងការទទួលស្គាល់ជាផ្លូវការនូវកម្លាំងសេវាសង្គម | $11,630 | $13,125 | $0 | $0 | $0 | $24,755 |
